# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែមករា លេខ ១

ព.ស. ២៤៩៧ — គ.ស. ១៩៥៥

LIBRARY
INSTITUTE

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង ទំព័រ

*ផ្នែកសាសនា*

— សន្និតន័យពីប្រវត្តិព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា នាអតីតកាល ..... ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ..... ៨
— សីលធម៌ .................. យុនបណ្ណានុរក្ស ប៊ូ-ប៊ូ ...... ២២
— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម -ស៊ុម .... ៤២

*ផ្នែកអក្សរសាស្ត្រ*

— រឿងសៅរសោយ (តមក) ........ ព្រះមហាឧត្តមវិជ្ជា ប៊ុង—ប៉ម ... ៥៤
— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ- កន ......... ៥៩
— ដំណឹងតាមខ្យល់ក្នុងកន្ត្រាះ (តមក) ... លោក ផេង-ជ្រីវ ......... ៦៧
— រឿងបល្ល័ង្កទិព្យ (តមក) .......... លោកវ៉ាយ- ប៊ុក ......... ៧៣

*កំណត់ទីនប្រវត្តិការណ៍*

— បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី ... (តមក) ក្រសួងធម្មការ ...... ៧៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ២១០៛.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique


## TABLE DES MATIÈRES


| | | Page |
|---|---|---|
| **PARTIE RELIGIEUSE:** | | |
| — Aperçu sur l'histoire du Bouddhisme au cambodge . . . . | Commission des Moeurs et coutumes . . . . | 8 |
| — Siladharma . . . . . . . . | M. BOU-PO . . . . . . . . . | 22 |
| — Pannasajataka- vol. 3 (suite) . | M. CHHIM-SOUM . . . . . . | 42 |
| **PARTIE LITTERAIRE:** | | |
| — Le «SAU SOY» ou l'influence saturnienne (suite) . . . . . | vén. PEUNG-PAM . . . . . . | 54 |
| — Histoire de samkok (suite). . | oknha NOU-KAN . . . . . . | 59 |
| — Le souffle du désert (suite) . . | M. PHENG-CHRIV . . . . . . | 67 |
| — des trente deux récits du trone (suite) . . . . . . . . . . | M. RAY-BUC . . . . . . . . | 73 |
| **NOTES ET CHRONIQUES:** | | |
| — Nomination des nouveaux chau-Adhikar (suite) . . . . . . . | Ministère des Cultes . . . | 79 |



Prix d'abonnement annuel (comprenant 12 numéros) 210$00

## វិចារណកថា

នយោបាយ ជាគុណជាតសម្រាប់ពិភពលោកខាងផ្លូវសម្ភារៈ, សាសនា ជាគុណជាតិសម្រាប់ពិភពលោកខាងផ្លូវចិត្ត ។ នយោបាយ ជាកង់ម្ខាងសម្រាប់រៀបចំប្រទេស ហៅថា អាណាចក្រ, សាសនា ជាកង់ម្ខាងសម្រាប់អប់រំចិត្តប្រជាជន ហៅថា សាសនចក្រ ឬធម្មចក្រ ។ ធម្មតារថ ឬរទេះ លុះតែកង់ទាំងឆ្វេងស្តាំវិលស្មើគ្នា មិនអាក់អួល ទើបលឿនទៅបាន, ប្រទេសនីមួយៗក៏ដូចគ្នា លុះតែអាណាចក្រ និងធម្មចក្រ ដែលទុកដូចកង់ទាំងពីរវិលស្មើគ្នា មិនឆាស់ មិនគាំងម្ខាងៗ ទើបលឿនទៅរកសេចក្តីសុខសេចក្តីចម្រើន ដោយសន្តិភាពបាន ។

ហេតុដូច្នេះ, បានជាប្រទេសទាំងពួងក្នុងសាកលលោក តែងបង្កើតវិជ្ជាឋានខាងអាណាចក្រសម្រាប់បង្រៀនខាងផ្លូវនយោបាយរៀបចំប្រទេស, ខាងធម្មចក្រសម្រាប់បង្រៀនអប់រំប្រជាជនខាងផ្លូវចិត្ត ដើម្បីឲ្យបានឋានៈជាអារ្យជន អារ្យប្រទេស ។

រាជរដ្ឋាភិបាលយើង បានជ្រាបការណ៍នេះ ទើបបានបង្កើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យឡើង ប្រតិស្ឋានកណ្តាលព្រះរាជធានី ភ្នំពេញ ។ វិជ្ជាឋាននេះ បានចាត់ការរៀបរៀងនិងរៀបចំបោះពុម្ពផ្សាយ នូវសៀវភៅធម៌អាថ៌ក្បួនច្បាប់ផ្សេងៗ ដែលទាក់ទងដោយវិជ្ជាខាងព្រះពុទ្ធសាសនា និងខាងអក្សរសាស្ត្រ ព្រមទាំងបានផ្សាយចេញនូវទស្សនាវដ្តីមួយ

មាននាមថា ទស្សនាវដ្ដីកម្ពុជសុរិយា ដែលលោក-អ្នកកំពុង
អាននេះ ។

យើងសូមធ្វើបទពិចារណា ចំពោះទស្សនាវដ្ដីនេះ ដូចតទៅ :

ក)- ទស្សនាវដ្ដីកម្ពុជសុរិយា ប្រែថា "សៀវភៅចេញរាយសម្រាប់អានវិលវង់តាមកាលកំណត់ ដូចព្រះអាទិត្យវិលបំភ្លឺប្រជាជនកម្ពុជា" ។ ធម្មតាសៀវភៅដែលហៅថាទស្សនាវដ្ដី គេតែងតែចុះអត្ថបទលាយចម្រុះ សម្រាប់អានតខ្សែសេចក្ដីគ្នាជាហូរហែតាមលំដាប់ថ្ងៃ-ខែ-ឆ្នាំ ដែលគេកំណត់ទុកហើយ ស្រដៀងគ្នានឹងសារព័ត៌មាន, អត្ថបទខ្លីៗ ដែលល្មមចុះមួយសៀវភៅចប់ក៏ចុះចម្រុះគ្នាឲ្យចប់ៗទៅ, អត្ថបទវែងៗ ចុះមួយសៀវភៅមិនចប់ ដោយលៃទំព័រទុកចុះអត្ថបទឯទៀតផង ក៏ចុះតៗទៅជាច្រើនសៀវភៅ ត្រាតែចប់; បើមិនចុះចម្រុះអត្ថបទច្រើនទេ ចុះតែអត្ថបទមួយ មួយសៀវភៅ នឹងក្លាយទៅជាសៀវភៅធម្មតា មិនមែនជាទស្សនាវដ្ដី ។ ហេតុនេះ, បានជាទស្សនាវដ្ដីកម្ពុជសុរិយានេះ មានចុះចម្រុះអត្ថបទ ចម្រុះរឿង ដូចរឿងសាមកុកជាដើម បន្តិចម្ដងៗ ដរាបដល់ចប់ទើបឈប់ ។

ខ)- កំណើតទស្សនាវដ្ដីកម្ពុជសុរិយា ទស្សនាវដ្ដីនេះកើតពី
ព.ស. ២៤៧០ (គ.ស. ១៩២៨) មកដល់ ព.ស. ២៤៩៧ (គ.ស. ១៩៥៤)

បាន ២៧ ឆ្នាំហើយ មិនដែលលេចផុតទស្សនាវដ្ដីទាំងពួងក្នុងកម្ពុជរដ្ឋ ដែលកើតឡើងហើយ ច្រើនតែបាត់លេចនោះឡើយ, ដោយសារពុទ្ធបរិស័ទដែលធ្លាប់បានគ្រប់អត្ថរសទស្សនាវដ្ដីនេះ ពេះតែនិយមអានជាហូរហែមិនដាច់ ទើបទស្សនាវដ្ដីនេះរស់កនមានជីវិតដរាបមកបាន ។

គ )- វត្ថុបំណងនៃទស្សនាវដ្ដីកម្ពុជសុរិយា យើងត្រូវការផ្សាយនូវអត្ថបទដែលទាក់ទងដោយពុទ្ធវចនៈឬដោយរឿងជាពុទ្ធសាសនា ទោះបីត្រូវផ្សាយនូវសាស្ត្រាល្បែង (រឿងប្រលោមលោក) ដែលទាក់ទងដោយអក្សរសាស្ត្រផង ក៏ផ្សាយបានតែរឿងដែលមិនទំនាស់ទឹងព្រះពុទ្ធសាសនា ហើយជារឿងបានគតិខាងផ្លូវទម្រុឌទម្រាមកិលេសប៉ុណ្ណោះ, ពីព្រោះទស្សនាវដ្ដីនេះ ជារបស់ពុទ្ធសាសនបណ្ឌិត្យ (ក្រសួងផ្សាយពុទ្ធសាសនា) ដែលត្រូវការណែនាំពុទ្ធជនឲ្យដើរតាមសម័យព្រះធម៌គ្រប់គ្រងលោក, មិនត្រូវការណែនាំពុទ្ធជនឲ្យរត់តាមសម័យកិលេសគ្រប់គ្រងលោកទេ ។

ឃ )- ក្របមុខនិងសណ្ឋានទស្សនាវដ្ដីកម្ពុជសុរិយា យើងគិតផ្លាស់ប្ដូរខ្លះដែរ តែដោយទើបនឹងផ្លាស់ថ្មីៗផង ដោយឃើញថាការផ្លាស់ប្ដូរមិនជាប្រយោជន៍ប៉ុន្មានផង ក៏ផ្អាកសិនទៅ. ប៉ុន្តែបើតាមការពិតក្របមុខទស្សនាវដ្ដី បើបានជាធ្វើបែបណាទៅហើយគួរតែទុកបែបនោះជាយីហោទៅស្រួលជាង, ឧបមាថាបើដាក់ក្នុងចំណោមសៀវភៅច្រើនមុខ

ឲ្យអ្នកផងក្រឡេកឃើញជាប់ស្គាល់ ជាទស្សនាវដ្ដីនេះ ទស្សនាវដ្ដីនោះបានក្លាយ ៗ ទោះបីគ្របខាងក្រៅមិនសូវល្អក៏ដោយ ឲ្យតែសេចក្ដីខាងក្នុងល្អក៏ទុកជាបានការ, ដូចផ្លែខ្នុរណាំ ៗ ដែលសម្បកក្រៅគ្រាតគ្រាត តែក្លូបខាងក្នុងផ្អែមឆ្ងាញ់ពិសាជាងផ្លែល្ហា ដែលសម្បកក្រៅរលោងស្រិល ៗ បើចង់ពិសោធន៍ការនេះ សូមធៀបគ្នាមើល សៀវភៅរបស់បណ្ណាគារផ្សេង ៗ ដែលគ្របមុខមានពណ៌ទឹកក្បាច់ក្បូរល្អ ៗ ហើយនឹងសៀវភៅគិហិបដិបត្តិជាដើម របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យដែលមានគ្របមុខខាងក្រៅលាត ឥតពណ៌ ឥតក្បាច់ តែសាច់ធម៌ខាងក្នុងល្អ មានប្រយោជន៍ចំពោះពុទ្ធបរិស័ទ ដែលមួយមុខ ៗ បោះពុម្ពមួយលើក ៗ ច្រើនម៉ឺនក្បាល ច្រើនលើក ច្រើនលានក្បាលទៅហើយ នៅតែមិនទាន់ផ្គត់ផ្គង់ផង តើខាងណាមានអ្នកនិយមអានច្រើនជាងខាងណា ?

ង)– ដំឡៃទស្សនាវដ្ដីកម្ពុជសុរិយា យើងចង់បន្ថែមទំព័រនឹងចង់ឲ្យថោក តែធ្វើទៅពុំកើតដោយរោងពុម្ពចេះតែដំឡើងថ្លៃបោះពុម្ពរាល់ឆ្នាំ យើងក៏ត្រូវតែដំឡើងថ្លៃតាមខ្លះ, ប៉ុន្តែដោយអនុគ្រោះប្រជាជន យើងក៏គិតឲ្យតែគ្រប់គ្រាន់ដំឡៃបោះពុម្ពនឹងដំឡៃចាត់ចែងការផ្សាយប៉ុណ្ណោះ ។ បើយកដំឡៃសៀវភៅរបស់បណ្ណាគារផ្សេង ៗ ហើយនឹងដំឡៃសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ មានគិហិបដិបត្តិជាដើម មកប្រៀបផ្ទឹមគ្នាមើល នឹងឃើញថាខាងក្រសួងនេះថោកជាង ។

ក្រៅពីទស្សនាវដ្ដីកម្ពុជសុរិយា, សព្វថ្ងៃនេះ យើងមិនមែនឈរទ្រឹងស្ងៀមព្រងើយទេ យើងបានបោះពុម្ពសៀវភៅទាំងចាស់ទាំងថ្មី, សៀវភៅចាស់ៗ ដូចគិហិបដិបត្តិជាដើម, ថ្មីៗ ដូចព្រះត្រៃបិដកជាដើម ដែលចេញផ្សាយតាមលេខរៀងៗ គ្នាទៅមុខៗ ប្លែកៗ ឈ្មោះ, ហើយការបោះពុម្ពនោះទៀត យើងបោះតាមតែសេចក្ដីត្រូវការប្រជាជននឹងតាមចំនួនប្រាក់ថវិកាជាតិ ដែលយើងធ្វើដូច្នេះ មិនមែនដោយខ្វះអ្នកនិពន្ធទេ គឺខ្វះប្រាក់ចំណាយ; ចាំពេលណាសម្បូរប្រាក់ យើងនឹងបំពេញចិត្តលោកអ្នកអាន ដោយចេញសៀវភៅថ្មីៗ ចម្លែកៗ ដែលជាស្នាដៃអ្នកនិពន្ធជំនាញៗ តទៅ ។

## និគមវចនៈ

ទស្សនាវដ្ដីកម្ពុជសុរិយា　　ពិរោះពិសាឆ្ងាញ់ឈ្ងុយឈ្ងិត
សម្រាប់តែពុទ្ធជនពិត　　ដែលមានគំនិតជូនខាងធម៌ ។
មិនមែនសម្រាប់លោកជន　　ដែលជូនខាងកាមាវចរ
ពីព្រោះមានគោលដំបរ　　ត្រូវផ្សាយតែធម៌នៃព្រះពុទ្ធ ។
ទោះបីផ្សាយរឿងអក្សរសាស្ត្រ　　ក៏មានឱកាសចេញផ្សាយសុទ្ធ
តែរឿងមិនទាស់មិនពិរុទ្ធ　　នឹងគោលព្រះពុទ្ធសាសនា ។

# ផ្នែកសាសនា

## សង្ខិត្តន័យពីប្រវត្តិព្រះពុទ្ធសាសនា
## នៅប្រទេសកម្ពុជាជាអតីតកាល

របស់

## លោក ហ្សង់-ប័ស្សលីយេរ

*ប្រតិភូសាលាបារាំងសែសនៅចុងបូព៌ាប្រទេស*

*អភិរក្សសារមន្ទីរអាល់ប៊ែរសារ៉ូត៍*

### ក្រុមជំនុំទំនៀមទម្លាប់ខ្មែរប្រែសម្រួល

ដូចតទៅនេះ:

ឯកសារដ៏ចាស់ជាងគេបំផុត ដែលដំណាលពីប្រវត្តិប្រទេសកម្ពុជាជំនាន់ដើមនោះ គឺសិលាចារឹកនៅ វ៉ូ-ចាញ់ (Vo-Canh) ។ សិលាចារឹកនេះពិតមែនតែគេរកឃើញនៅភូមិភាគញ៉ាត្រាំង (Nha-Trang) តែគេអាចស្គាល់បានថាជារបស់ហ្វូណន ។ សិលាចារឹកនេះចាប់កំណើតឡើងក្នុងសតវត្សរ៍ទី ៣ នៃគ្រិស្តសករាជ ជាអត្ថបទលិខិតដ៏បូរាណបង្អស់មួយនៃប្រទេសហ្វូណនផង ជាភស្តុតាងនៃការឧបត្ថម្ភព្រះពុទ្ធសាសនារបស់ព្រះរាជាសម័យនោះផង ។ សូម្បីគេចារឹកភាសាសំស្ក្រឹតក្នុងផែនសិលានោះជាផ្លូវការក៏ដោយ, តែព្រះពុទ្ធសាសនាសម័យនោះប្រាកដជាព្រះពុទ្ធសាសនា

ទក្ខិណនិកាយដោយពិត, ឯលទ្ធិឧត្តរនិកាយគេប្រតិបត្តិក្នុងកាលមកជាក្រោយទេ មិនមែនមុនសតវត្សរ៍ទី ៧ នៃគ្រិស្តសករាជឡើយ ។ បំណែកភាសាបាលីប្រហែលគេចាប់ផ្ដើមប្រើមុនដំបូងនៅពុទ្ធសករាជ ១.៨៥២ គ្រិស្តសករាជ ១.៣០៩ ។

## សម័យហ្វូណនមកដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី ២

ក្នុងថេរកាលនៃសតវត្សរ៍ទី ៤ នៃគ្រិស្តសករាជ យើងខ្វះខាតសេចក្ដីឲ្យការណ៍ទាំងស្រុង ។ សេចក្ដីរាយការណ៍ជាប្រភពចិនដែលមានដំណាលពីជីវភាពប្រទេសហ្វូណន ក៏មានពិស្ដារណាស់ដែរ តែមិនសូវឃើញមានដំណាលពីសាសនា ដែលគេគោរពក្នុងសម័យនោះឡើយ ។

រវាងពុទ្ធសករាជ ១.០២៣ គ្រិស្តសករាជ ៤៨០ ប្រវត្តិរាជវង្សត្ស៊ី (T'si) ប៉ែកខាងត្បូងមានសេចក្ដីរាយការណ៍ច្រើន ផ្ទុយនឹងសេចក្ដីខាងដើមស្រឡះ សេចក្ដីថា: «ការគោរពព្រះឥសូរ និងព្រះវិស្ណុក្នុងសម័យនោះជាកិច្ចសំខាន់ណាស់ តែទោះជាយ៉ាងណាក៏ព្រះពុទ្ធសាសនាក៏ចាក់ឫសជាក់គល់ទូលំទូលាយណាស់ដែរ» ។ ក្នុងពុទ្ធសករាជ ១.០២៧ គ្រិស្តសករាជ ៤៨៤ ព្រះបាទកោណ្ឌិន្យជយវរ្ម័នបានបញ្ជូនភិក្ខុជាតិហ្វូណនមួយអង្គ នាម នាគសេនៈ ជាបេសកសមណៈទៅកាន់ព្រះរាជសំណាក់ព្រះអធិរាជចិន ។ នៅក្នុងរជ្ជកាលនេះភិក្ខុជាតិហ្វូណនពីរអង្គគឺ ព្រះថេរៈនាម សង្ឃបាលៈ និងព្រះថេរៈនាម មន្ទ្រសេនៈ បានតាំងជាវត្តអារាម

នៅប្រទេសចិនហើយ ព្រមទាំងបានប្រែព្រះត្រៃបិដកផង, ឯសេចក្ដីប្រែនោះឃើញមានប្រាកដនៅក្នុងបិដកចិនជាបន្ទាល់ស្រាប់ ។

ក្នុងរជ្ជកាលព្រះបាទរុទ្រវរ្ម័ន ជាព្រះរាជាចុងក្រោយបង្អស់នៃប្រទេសហ្វូណន ព្រះពុទ្ធសាសនាក៏មានជំហរបន្ទាប់បន្សំទៅឡើយ ដូចជាសេចក្ដីក្នុងសិលាចារិកនៅប្រាសាទតាព្រហ្ម (ស្រុកបាទី) បានចែងទុកថា “ការគោរពព្រះបរមសារីរិកធាតុតាមសណ្ដាប់ថេរវាទតែម្យ៉ាង ដែលគេប្រតិបត្តិក្នុងសម័យនោះ” ។ ព្រះបាទរុទ្រវរ្ម័នព្រះអង្គលោកមិនជាពុទ្ធសាសនិកពិតមែនទេ តែទ្រង់បានសំដែងព្រះអង្គឲ្យព្រះអធិរាជប្រទេសចិនឃើញថាទ្រង់គោរពព្រះបរមសារីរិកធាតុ ដ៏មានតម្លៃបំផុត គឺព្រះកេស ១ សរសៃនៃព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ។

ក្នុងកាលខាងក្រោយអំពីរជ្ជកាលព្រះបាទរុទ្រវរ្ម័នមក ស្រាប់តែបាត់ដំណឹងសូន្យឈឹង ស្ទើរតែអស់មួយសតវត្សរ៍ទៀត, សព្វថ្ងៃនេះយើងពុំទាន់បានដឹងនៅឡើយថា មានហេតុកើតព្រះពុទ្ធសាសនាដូចម្ដេចខ្លះអំពីការរួបរួមប្រទេសចិនឡានេះ ។ កាលពីពុទ្ធសករាជ ១.១៧០ គ្រិស្ដសករាជ៦២៧ មានសិលាចារិកនៅវិទ្យាវិសេសៈមួយទៀត គេទុកជាឯកសារមួយដែលស្ដីពីព្រះពុទ្ធសាសនានៅក្នុងសម័យនោះ, តមកក៏បាត់ដំណឹងសូន្យឈឹងទៀត រហូតមកដល់ទីបំផុតនៃសតវត្សរ៍ទី ៧ នៃគ្រិស្ដសករាជ ។ បុដនិយេសក៍ចិនម្នាក់ជាបព្វជិតឈ្មោះ យី-ត្សីង

(Yi-Tsing) ដែលធ្វើដំណើរឆ្លងកាត់ទ្វីបអាស៊ីភាគអគ្នេយ៍ នៅរវាងពុទ្ធសករាជ ១.២១៤ ទៅ ១.២៣៨ គ្រិស្តសករាជ ៦៧១ ទៅ ៦៩៥ បានសរសេរទុកថា: "ព្រះពុទ្ធវចនៈចំរើនរុងរឿងហើយផ្សាយទូទៅ, ប៉ុន្តែសព្វថ្ងៃនេះ មានព្រះរាជាមួយព្រះអង្គកាចឃោរឃៅបានបំផ្លិចបំផ្លាញព្រះពុទ្ធវចនៈពេលអស់ ឥតមានភិក្ខុសង្ឃសោះឡើយ . . ." ។ មិនសមបើមានអំពើយង់ឃ្នងដែលកម្រមានណាស់ នៅប្រទេសកម្ពុជាដូចជាបណ្ឌិត យី-ត្សីង បានពោលថាកាចកំរោលនោះសោះ ព្រោះមានសិលាចារិកខ្លះនិយាយថា មានគសាងវត្តអារាមនៅឡើយរវាងជំនាន់ដដែលនេះ ។ ទោះជាម្តេចម្តាក៏ដោយប្រហែលជាមានប្រតិកម្មយ៉ាងនេះជាផ្លូវការពិតមែនក៏មិនដឹង បានជាលទ្ធិព្រះពុទ្ធសាសនាថេរវាទសាបរលាបសូន្យទៅ ពីព្រះរាជអាណាចក្រខ្មែរអស់កាលជាច្រើនសតវត្សរ៍ ។ កាលនោះ ព្រះពុទ្ធសាសនាលទ្ធិមហាយានចាប់ផ្តើមចំរើនតក់ៗ ឡើងវិញ ។ ឯសិលាចារិកដែលមានស្តីពីលទ្ធិមហាយាននេះ គឺសិលាចារិកនៅពុទ្ធសករាជ ១.៣២៤ គ្រិស្តសករាជ ៧៨១ ប៉ុន្តែបើយកទេវរូបដែលចាស់ជាងគេមកប្រៀបធៀបវិញឃើញថា ទេវរូបទាំងនេះកើតឡើងតាំងពីកាលសតវត្សរ៍ទី ៧ នៃគ្រិស្តសករាជម្ល៉េះ ។ មួយទៀត, យើងត្រូវកំណត់ចាំថាប្រទេសដែលបានទទួលអារ្យធម៌ប្រទេសឥណ្ឌា មិនដែលឃើញប្រទូសរ៉ាយចំពោះព្រះពុទ្ធសាសនាលទ្ធិមហាយានឡើយ កាល

ពីមុន ដាច់សតវត្សទី ៧ នៃគ្រិស្តសករាជ (សុម៉ាត្រាប្រទេសជ្វា) បើយើងយកការបទានលក្ខណៈនៃទេវរូបមកជាគ្រឿងសំគាល់វិញ ឃើញថាទើបតែកើតមានច្រើននៅក្នុងរយកាលនៃសតវត្សរ៍ទី ៨ នៃគ្រិស្តសករាជទេ ។ ឯទេវរូបទាំងនោះច្រើនតែកសាងឡើងតំណាងលោកកេស្វរៈជាពោធិសត្វប្រកបដោយមេត្តា ។

ក្នុងរយកាលនៃសតវត្សរ៍ទី ៩ នៃគ្រិស្តសករាជ ក្រោយដែលគេវិលងគោរពពោធិសត្វលោកេស្វរៈជាលំដាប់មក ទេវរូបទីងសិលាចារិកខាង ព្រះពុទ្ធសាសនាលទ្ធិមហាយាន ក៏ហាក់ដូចជាអន្តរធានសាបសូន្យអស់ទៅ ។ ការអន្តរធាននេះប្រហែលជាកើតឡើងអាស្រ័យដោយការបង្កើតការគោរពព្រះឥសូរ នៃ ព្រះបាទជយវរ្ម័នទី ២ (ព. ស. ១.៣៤៥-១.៣៩៣ គ. ស. ៨០២-៨៥០) ឡើងវិញ ។ ព្រះរាជាទ្រង់មាន ព្រះរាជបំណងនឹងស្ថាបនា ព្រះរាជានុភាពដោយយកសាសនាជាបាទ ពឹងផ្អែកទៅលើពួកព្រាហ្មណ៍ ហើយទ្រង់មិនបានទទួលសេចក្ដីយល់ព្រមការពារជាផ្លូវការដល់ ព្រះពុទ្ធសាសនាឡើយ, ត្រង់នេះ យើងត្រូវចាំមើលក្នុងរជ្ជកាលនៃ ព្រះរាជាជាតំណាងវង្សទីពីរ គឺ ព្រះបាទឥន្ទ្រវរ្ម័នតទៅ ដើម្បីនឹងដកស្រង់យកអត្ថបទដែលនិយាយដល់ការសៀមភក្តិចំពោះព្រះពុទ្ធ-សាសនា គឺសិលាចារិកនៅបាន-បុង-កែ (Ban-Bong Kè) ។

# ការកសាងក្រុងអង្គរហូតដល់ចាមវាយយកអង្គរបាន

ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន ជាព្រះរាជាកសាងក្រុងយសោធរៈបុរៈ ជាក្រុងអង្គរជាន់ដើម យើងបានឃើញគេទទួលស្គាល់ព្រះពុទ្ធសាសនាជាផ្លូវការ, នេះហើយជាប្រវត្តិមុនដំបូងនៅប្រទេសខ្មែរ ។ សិលាចារឹកថែងថា ព្រះរាជាទ្រង់បានកសាងវត្តអាស្រមជាច្រើន ជាវត្តសម្រាប់ព្រះឥសូរខ្លះ សម្រាប់ព្រះវិស្ណុខ្លះ សម្រាប់ព្រះពុទ្ធសាសនាខ្លះ សាសនាទាំងនេះបានទទួលសិទ្ធិនិងបុព្វសិទ្ធិយ៉ាងម៉ឺងម៉ាត់ដូចគ្នា ។ បើទុកជាសិលាចារឹកថែងថា ព្រះរាជាទ្រង់អនុញ្ញាតឲ្យកាន់សាសនាតាមចិត្តដ៏ទូលាយយ៉ាងនេះក៏ដោយ តែក៏គង់សំដែងឲ្យឃើញច្បាស់ថា ព្រះពុទ្ធសាសនាមានការអើពើជាងការគ្រប់គ្រង ដោយសមភាពចំពោះសាសនាឯណាដែរ ។

ក្រោយរជ្ជកាលរុងរឿងនៃព្រះបាទយសោវរ្ម័ន, ព្រះពុទ្ធសាសនាជាផ្លូវការធ្លាក់ចុះមកកាន់ការស្ងប់ស្ងៀមមួយលើកទៀត, ប៉ុន្តែការកសាងវត្តអាស្រមជាអនេកនៅមានប្រាកដក្បែរព្រះរាជធានីនៅឡើយ ដោយច្រើនចំពោះភាគទីពីរនៃសតវត្សរ៍ទី ១០ នៃគ្រិស្តសករាជ ។ ទេវស្ថាន ៣ កន្លែងនៅបាតជុំ ជាទេវស្ថាននៃព្រះរាជាគណៈមួយអង្គក្នុងបណ្តាព្រះរាជាគណៈទាំងឡាយដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាងគេ គឺមួយឧទ្ទិសដោយគោរពចំពោះព្រះពុទ្ធ មួយទៀតចំពោះនាងវជ្របាណី

មួយគឺទៅទៀតចំពោះនាងប្រាជ្ញាបារមីតា ។ ផែនសិលានៅវត្តស្រីសុទ្ធរ មុនការកសាងទេវស្ថាននេះមិនយូរប៉ុន្មានមានចែងសារៈសំខាន់ថា "លទ្ធិព្រះពុទ្ធសាសនាមានគេប្រតិបត្តិរហូតដល់ទៅក្បែរ ១ ព្រះរាជវង្សានុវង្សផង" ។ លទ្ធិព្រះពុទ្ធសាសនានេះសរសេរទៅរកខាងនិកាយយោគាចារៈ ដែលជាសារៈសំខាន់មួយខាងការគោរពពោធិសត្វលោកេស្វរៈ ។

ក្នុងរជ្ជកាលនៃព្រះបាទសូរ្យវរ្ម័នទី ១ (ព.ស. ១.៥៤៥ - ១៥៩៣ គ.ស. ១០០២ - ១០៥០) ព្រះពុទ្ធសាសនាមិនមែនគ្រាន់តែព្រះរាជាទទួលស្គាល់ជាផ្លូវការប៉ុណ្ណោះទេ គឺព្រះរាជាទ្រង់ថ្វាយការអើពើហើយទ្រង់គោរពប្រតិបត្តិថែមទៀតផង ។ ព្រះរាជាអង្គនេះទ្រង់ជាសាវ័កពិតប្រាកដរបស់ព្រះពុទ្ធសាសនា កាលទ្រង់ទីវង្គតទៅ គេថ្វាយព្រះមរណនាមព្រះអង្គថាព្រះបាទនិព្វានបទ សឲ្យឃើញច្បាស់ប្រាកដ, ប៉ុន្តែពុំបីមានការសាងទេវស្ថានចំរើនឡើង ប្រកបដោយរូបចម្លាក់ខាងព្រះពុទ្ធសាសនាព្រមទាំងព្រះពុទ្ធរូបទាំងនេះ ដូចព្រះពុទ្ធរូបប្រក់នាគមុចលិន្ទជាដើមគ្គ គឺការគោរពរបស់ព្រះរាជាមិនមែនគ្មានការផ្លាស់ប្តូរទេ ។ សិលាចារឹកនៅស្តុកកោះធំបានពោលបញ្ជាក់ពីប្រវត្តិត្រកូលព្រាហ្មណ៍ជាន់ខ្ពស់ម្នាក់ ស្តីចំពោះការផ្លាស់ប្តូរនេះថា: "នៅក្នុងរជ្ជកាលព្រះបាទនិព្វានបទ ព្រះរាជវង្សានុវង្សទាំងអស់គោរពបូជាទេវរាជតាមព្រះរាជឱង្ការ" ។

ក្រោយរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១ មានការកសាងទេវស្ថាន និងសិលាចារឹកជាភស្តុតាងផងដែរ សំដែងឲ្យឃើញថាការគោរពព្រះពុ-

សាសនាជាប់តំណរវង្សត្រូវគ្នាដើកនៅក្រោមបដាលដាប់មក ។ តាមសេចក្តីក្នុងព្រះមរណនាម, ព្រះរាជាទាំងឡាយគង់នៅតាមទំនៀមហិណ្ឌូសម័យបុរាណ តែនាម៉ឺនមុខមន្ត្រីនៅតែប្រតិបត្តិតាមព្រះពុទ្ធសាសនា ឥតសង្ស័យឡើយ ។ ឯព្រះពុទ្ធសាសនាលទ្ធិមហាយានចំនងជាចូលដៃនឹងពួកអ្នកប្រាជ្ញសាសនាពួកខ្លះ បានជាក្នុងមជ្ឈដ្ឋាននាម៉ឺនមុខមន្ត្រីទាំងនោះមានត្រកូលមួយបកូលក្នុងវង្សការយ៉ាងសំខាន់ក្នុងប្រវត្តិ គឺរាជវង្សមហីធរបុរៈឡើងកាន់អំណាចក្នុងពុទ្ធសករាជ ១.៦២៣ គ្រិស្តសករាជ ១.០៨០ ។

ពោះបីព្រះបាទសូរ្យវរ្ម័នទី ២ ជាព្រះរាជាមានព្រះកេរ្តិ៍ដ៏សម្បើមក្នុងព្រះរាជវង្សនោះ ទ្រង់គោរពព្រះវិស្ណុ ហើយទ្រង់បានកសាងប្រាសាទនគរវត្តល្បីល្បាញក៏ដោយ, តែព្រះរាជាជាតំណរវង្សមកត្រឡប់ទៅជាកាន់ព្រះពុទ្ធសាសនាយ៉ាងស្មោះស្ម័គ្រទៅវិញ ដោយទ្រង់សព្វព្រះទ័យក្រេបវិមុត្តិរសនៃព្រះសាសនាព្រះសក្យមុនី តែប៉ុណ្ណោះ, តែទ្រង់មិនបានតាំងនៅក្នុងព្រះរាជសម្បត្តិមុតមាំប៉ុន្មានទេ, លុះដល់ព្រះរាជបុត្រព្រះអង្គគឺព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់មានជ័យជំនះទ្រង់បានដេញចាមដែលលុកលុយបណ្តាលឲ្យចលាចលពាសពេញប្រទេសក្នុងសតវត្សរ៍ទី ១២ នៃគ្រិស្តសករាជ នោះបានសាន្តត្រាណ ហើយទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាតាមរបៀបច្បាប់ថ្មីរឹងប៉ឹង មានរបៀបរៀបរយចំរើនល្អគួរលាស់ដូចដើមឡើងវិញ ។

## ព្រះបាទជ័យវរ្ម័នទី ៧

ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់មានការកិច្ចសម្បើមអស្ចារ្យណាស់គឺត្រូវដណ្តើមប្រទេសឲ្យបានផុតចេញពីអ្នកលុកលុយ, ត្រូវរៀបចំឲ្យប្រទេសសាន្តត្រាណ, ត្រូវជួសជុលព្រះរាជានុភាពឡើងវិញ..., ទាំងអស់នេះទ្រង់ត្រូវតែបំពេញដោយព្រះរាជឆន្ទៈដ៏មុតមាំ ជាសេចក្តីអង់អាចរបស់ព្រះអង្គ ដែលប្រជារាស្ត្រប្រកបដោយសេចក្តីស្នេហាជ្រាលជ្រៅដកចិត្តចេញពុំបាន បានទាំងជួយព្រះអង្គដោយដំនឿដ៏ខ្លាំងក្លាផង ។ ទ្រង់មានព្រះរាជបំណងវាតពង្រីកព្រះតេជានុភាព តាមគន្លងឧត្តមគតិមហាករុណាធិគុណទ្រង់ប្រកបព្រះរាជជីវភាពព្រះអង្គ តាមចរិយាព្រះពោធិសត្វអវលោកិតេស្វរៈ ដូចសិលាចារិកតំកើងព្រះអង្គថា: "ទ្រង់រងទុក្ខវេទនាចំពោះជម្ងឺប្រជារាស្ត្រព្រះអង្គ ជាងព្រះអាពាធចំពោះព្រះកាយព្រះអង្គ ព្រោះទុក្ខវេទនាសាធារណជនជាទុក្ខវេទនានៃព្រះរាជា មិនមែនជាសេចក្តីទុក្ខចំពោះព្រះអង្គទេ". (នៃសិលាមន្ទីរពេទ្យ) ទ្រង់គោរពសេចក្តីថា "មគ៌ាដ៏ប្រសើរបំផុតដែលនាំទៅកាន់សម្មាសម្ពោធិញ្ញាណគឺលទ្ធិឯកឥតមានមន្ទិលសៅហ្មង ដើម្បីការយល់ច្បាស់នូវសេចក្តីពិត (យថាភូតទស្សនញ្ញាណ) ព្រះធម៌នោះអមតបុគ្គលក្នុងនៃត្រៃលោកត្រូវគោរពបូជា ទុកជាព្រះខ័នបំផ្លាញបង់នូវគុម្ពឈើ គឺកិលេសាសវៈ" (សិលាចារិកនៅតាព្រហ្ម) ។

ក្នុងនាមព្រះរាជសទ្ធាព្រះអង្គ, ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កសាង ទេវស្ថានច្រើនជាអនេកពាសពេញប្រទេស មានទេវស្ថានខ្នះធំអស្ចារ្យ មានមន្ទីរពេទ្យ អាស្រម និងសាលាសំណាក់ច្រើនកន្លែង ។ សាសនា ដែលគេគោរពនោះ គឺលទ្ធិមហាយានដែលរួមចុះនៅក្នុងគុណព្រះពុទ្ធ, ពោធិសត្វលោកេស្វរៈ, នាងប្រជ្ញាបារមីតា ព្រមទាំងពោធិសត្វដទៃទៀត ដែលមានគុណានុភាពបន្ទាប់បន្សំចុះមក ។ បើក្នុងរជ្ជកាលនេះ មានសេចក្ដីរុងរឿងដូចសេចក្ដីក្នុងសិលាចារិកថែងថា មានកសាងវត្តអារាមខាងព្រះពុទ្ធសាសនាក៏ដោយ, ឯពួកព្រាហ្មណ៍គេក៏មិនលះបង់ចោល ចេញពីក្នុងព្រះរាជករណីយកិច្ចទេ, ដូចជានៅបច្ចុប្បន្នកាលនេះ ពួកព្រាហ្មណ៍នៅតែប្រកបពិធីក្នុងព្រះរាជពិធីផ្សេង ៗ នៅឡើយ គឺគេនៅគោរពតាមទំនៀមដែលមានជាច្រើនសតវត្សរ៍មកហើយ តាំងពីព្រះបាទជ័យវរ្ម័នទី ២ម្ល៉េះ ។

បណ្ដាព្រះរាជបុត្រនៃព្រះបាទជ័យវរ្ម័នទី ៧ មានព្រះរាជបុត្រមួយព្រះអង្គដែលទ្រង់ស្ដេចចេញទៅបំពេញការសិក្សានៅកោះលង្កា ហើយទ្រង់បានបព្វជានៅប្រទេសនោះ (តាមទំនៀមភិក្ខុសង្ឃគណៈមហាវិហារ) ។ នេះជាកិច្ចការយ៉ាងសំខាន់មួយនៃព្រះពុទ្ធសាសនាលទ្ធិថេរវាទដែលមានចារិកនៅប្រទេសកម្ពុជា ហើយហាក់ដូចជាបានពន្លឺមួយឲ្យយល់សេចក្ដីពិតថា ព្រះពុទ្ធសាសនាលទ្ធិថេរវាទចំរើនលូតលាស់

ដុះដាលឡើងជាមួយគ្នា មួយអន្លើដោយព្រះពុទ្ធសាសនាលទ្ធិមហាយាន ដែលគេទុកជាផ្លូវការ ដោយហោចណាស់សេចក្ដីនេះអាចអុជព្រោលបំភ្លឺនូវការសិក្សាវិជ្ជារូបសាស្ត្រ (Iconographie) សម័យជាមួយគ្នាបាន កាលណាបើមិនមានសិលាចារឹកជាកស្តុតាង ។ ការដែលនាំឲ្យវិលត្រឡប់មកកាន់ព្រះពុទ្ធសាសនាដែលធ្លាប់ប្រតិបត្តិមកហើយ កាលពីប្រថមសតវត្សរ៍យ៉ាងនេះវិញ ទំនងជាដោយការទាក់ទងនឹងការចំរើនផ្លូវគមនាគមន៍ខាងជើងគោកជាមួយនឹងប្រជុំកោះខាងលិច ព្រោះនៅទីនោះព្រះពុទ្ធសាសនាលទ្ធិថេរវាទកំពុងដុះលូតលាស់រស់រវើកនៅឡើយ ។

## ព្រះរាជសន្តតិវង្ស នៃព្រះបាទជ័យវរ្ម័នទី ៧ រហូតដល់ប្រតិស្ឋានព្រះរាជធានីក្រុងភ្នំពេញ

ការគោរពព្រះពុទ្ធសាសនាតាមតម្រាយព្រះបាទជ័យវរ្ម័នទី ៧ ដែលទ្រង់បានខិតខំដោយព្រះរាជសទ្ធា នឹងដោយព្រះថាមពលដ៏មុតមាំយ៉ាងនេះ មិនបានឋិតថេរចិរកាលនៅយូរលង់ទៅបានទេ ក្នុងកាលជាខាងក្រោយពីកាលដែលទ្រង់បាត់បង់ទៅហើយ ។ ដោយពិតចាប់តាំងពីរាជសន្តតិវង្សទីពីរមក ប្រវត្តិប្រទេសខ្មែរមានប្រតិកម្មដ៏សាហាវប្លែកអស្ចារ្យណាស់ គឺព្រះរាជាអង្គក្រោយមិនពេញព្រះទ័យក្នុងការគោរពនូវទេវរូប ហើយព្យាយាមបំផ្លិចបំផ្លាញលុបដានតម្រាយព្រះពុទ្ធសាសនា

តាមដែលទ្រង់ស្អប់ខ្ពើមនោះដោយអំពើគាបដូចមនុស្សព្រៃ ៗ នៅប្រា-សាទពជស្ពានខ្លះ ឃើញមានស្នាមកោសលុបការរចនាទីងទេវរូបផ្សេង ៗ ជាស្នាដៃនៃពួកអ្នកបំផ្លិចបំផ្លាញ ដែលពេញចិត្តនឹងសាសនាព្រះឥស្សូរ, ដោយពិត ប្រហែលជារួមដៃជាមួយនឹងពួកអ្នកនាំខាងសាសនាព្រាហ្មណ៍ផង គឺពួកអ្នកដែលអស់អំណាចកាលដែល ព្រះបាទជយវរ្ម័នទី ៧ ធ្វើបដិវត្តន៍ខាង ព្រះពុទ្ធសាសនាឡើង. ពួកនេះប្រាថ្នាចង់ដណ្តើមយកអំណាចបុព្វសិទ្ធិពីដើមរបស់ខ្លួនដែលបាត់បង់ទៅមកកាន់វិញ, មួយទៀតព្រះរាជាអង្គថ្មីដែលឡើងគ្រងរាជបល្ល័ង្កឡើង ទំនងជាអ្នកជ្រែកពង្សឲ្យឱកាសដែលខ្លួនរង់ចាំមកយូរហើយផង ៗ

លុះដល់ ព្រះពុទ្ធសាសនាលទ្ធិមហាយានដែលដើរសំណាងនៅលើរបៀបរាជាធិបតេយ្យ ហើយអាប់ឱនរស្មីទៅក្នុងកាលជាមួយនេះផង, ឯ ព្រះពុទ្ធសាសនាលទ្ធិថេរវាទនៅមានសារៈមិនតិចប៉ុន្មានដែរ ក៏លូតលាស់ដុះដាលឡើងវិញ យ៉ាងឆាប់រហ័សក្នុងរវាងខាងចុងសតវត្សរ៍ទី ១៣ នៃគ្រិស្តសករាជ ៗ ត្រង់នេះ យើងត្រូវយកប្រាសាទអង្គរជំនាន់ក្រោយៗ ដែលកសាងដោយសម្ភារៈមាំ ៗ មកជាបន្ទាល់លទ្ធិថេរវាទនេះ ៗ លោកជៀវ-តាក្វន រាជទូតចិន ដែលមកកាន់ប្រទេសខ្មែរ កាលពុទ្ធសករាជ ១.៨៣៩ គ្រិស្តសករាជ ១.២៩៦ បានចែងទុកបញ្ជាក់ពីសាសនាដែលគេនិយមប្រតិបត្តិក្នុងសម័យនោះ ព្រមទាំងចុះសេចក្តីរាយការណ៍

សំខាន់ ៗ ដែលស្ដីពីច្បាប់ព្រះពុទ្ធសាសនា និងសេចក្ដីយការណ៍ខ្លះទៀតមិនសូវជាគ្រប់គ្រាន់ទេ តែជាសេចក្ដីបញ្ជាក់ដ៏មានតម្លៃគួរសម្រាប់អ្នកប្រវត្តិទាំងឡាយផង ។

លោក ចៀវ-តាក្វន បានឃើញសិលាចារិកជាភាសាបាលីដែលចាស់ជាងគេពីកាលជំនាន់ក្សត្រសោយរាជ្យបន្ទាប់តមក ។ សិលាចារិកនេះមានតាំងពីពុទ្ធសករាជ ១.៨៥២ គ្រិស្តសករាជ ១.៣០៩ ជាអនុស្សាវរីយ៍នៃការកសាងព្រះវិហារព្រមទាំងដំកល់ព្រះពុទ្ធរូបផង ។ ទោះបីព្រះពុទ្ធសាសនាលទ្ធិថេរវាទចំរើនរុងរឿង មានភស្តុតាងប្រាកដយ៉ាងនេះក៏ដោយ មិនមែនប្រែថាសាសនាព្រាហ្មណ៍សាបសូន្យទៅទេ ការគោរពសាសនាព្រាហ្មណ៍ក៏ចំរើនរុងរឿងខ្លាំងណាស់ដែរ នៅក្នុងផ្ទៃព្រះរាជវាំងក្នុងដើមសតវត្សរ៍ទី ១៤ នៃគ្រិស្តសករាជ, ឯពិធីព្រាហ្មណ៍ក្នុងបច្ចុប្បន្នកាលនេះទុកជាភស្តុតាង នៃការអាប់ឱនទៅរបស់សាសនាព្រាហ្មណ៍ក្នុងកាលនោះ ។

ចាប់តាំងពីនិពសអង្គរ គឺក្នុងរវាងខាងចុងសតវត្សរ៍ទី ១៥ នៃគ្រិស្តសករាជមក មិនមានសិលាចារិកស្ដីពីហេតុការណ៍អ្វីសោះ មានតែប្រវត្តិតែប៉ុណ្ណោះទេដែលមានរៀបរាប់ហេតុការណ៍ផ្សេងៗ ក្នុងសម័យកាន់ប្រែ ៗ តាមទំនងប្រហែលជាព្រះពុទ្ធសាសនាលទ្ធិថេរវាទចេះតែចំរើនតៗ មកដោយរហ័ស ព្រោះព្រះបាទពញាយ៉ាត ក្រោយដែលទ្រង់ទៅប្រថាប់នៅ

ក្រុងស្រីសុន្ទរមិនយូរប៉ុន្មាន ទ្រង់ប្តូរជាថានីងមកកសាងព្រះរាជធានីនៅក្រុងភ្នំពេញក្នុងបច្ចុប្បន្នកាលនេះ គឺនៅជុំវិញចេតិយធំមានកេរ្តិ៍ឈ្មោះនេះហើយ ដែលជាទីតាំងព្រះរាជធានីថ្មី ។ ភ្នំនេះជាមជ្ឈដ្ឋាននៃព្រះរាជធានីថ្មីជាទេវាល័យដម្កល់ព្រះទេវរាជជាប់ជាទំនៀមតមកដូចសតវត្សរ៍ដែលកន្លងមកយូរលង់ហើយ ។ វត្តអារាមទាំងប៉ុន្មានដែលទ្រង់កសាងសុទ្ធតែជាវត្តព្រះពុទ្ធសាសនា មានវត្តអារាមខ្លះដែលទ្រង់គោរពគេបានជួសជុលឋិតថេររហូតមកដល់សព្វថ្ងៃនេះ ។

ចាប់ពីខាងដើមសតវត្សរ៍ទី ១៥ នៃគ្រិស្តសករាជមក ព្រះពុទ្ធសាសនាចាក់ឫសគល់មាំជាស្ថាពរនៅក្នុងកម្ពុជរដ្ឋ, លុះក្រោយមកជិត ១២ សតវត្សរ៍ ទើបត្រឡប់មកកាន់ព្រះពុទ្ធសាសនាទក្ខិណនិកាយ ដូចសេចក្តីរៀបរាប់ក្នុងសិលាចារិកនៅវ៉ូ-ចាញ់ វិញ (Vo-Canh) មួយទៀត, ដល់មកសតវត្សរ៍ទី ១៦ នៃគ្រិស្តសករាជ ទោះបីជាតិពារទុយគេស៍ មានបំណងបង់បំផ្លាញព្រះពុទ្ធសាសនាយ៉ាងណាក៏ដោយ ក៏មិនអាចញ៉ាំងព្រះពុទ្ធសាសនាឲ្យកម្រើកញាប់ញ័ររលំឫសគល់បានឡើយ ។

សង្ខិតន័យពីប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសកម្ពុជានាអតីតកាលចប់ត្រឹមប៉ុណ្ណេះ ។

# ឃុនបណ្ឌានុរ័ក្ស ប៊ូ-ប៊ូ រៀបរៀង

សីលធម៌(១) ពាក្យនេះកាត់ជា ២ បទ គឺសីល ១ ធម៌ ១ ។ ការរក្សាកាយវាចាឲ្យរៀបរយល្អ ឲ្យប្រាសចាកទោស ហៅថា សីល បានដល់សីល ៥ សីល ៨ សីល ១០ សីល ២២៧ ។ សភាវៈដែលទ្រទ្រង់ ហៅថា ធម៌ ។

ពាក្យថា "ធម៌" នេះជារបស់កណ្ដាល គឺទ្រទ្រង់ទាំងខាងល្អ ទ្រទ្រង់ទាំងខាងអាក្រក់; បើខាងល្អ គឺទ្រទ្រង់អ្នកប្រព្រឹត្តល្អមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ហៅថា ធម៌ល្អ (កុសលធម៌), បើខាងអាក្រក់ គឺទ្រទ្រង់អ្នកប្រព្រឹត្តអាក្រក់ឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ហៅថា ធម៌អាក្រក់ (អកុសលធម៌) ។ ធម៌ក្នុងពាក្យថា សីលធម៌នេះ សំដៅយកធម៌ខាងល្អ ។

ក្នុងទីនេះ មិនបានអធិប្បាយអំពីសីលទេ ព្រោះមានសេចក្ដីពិស្ដារ ដូចលោក-អ្នកធ្លាប់ជ្រាបស្រាប់ហើយ សូមអធិប្បាយតែត្រង់ពាក្យថា ធម៌ឲ្យពិស្ដារបន្តិច ។

មនុស្សអ្នកមានធម៌នៅប្រចាំក្នុងចិត្ត ឬថាអ្នកប្រព្រឹត្តធម៌ជាប់ជានិច្ច ធម៌នោះតែងរក្សាអ្នកនោះមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់បាន ព្រោះសេចក្ដី

---

១ ច្បាប់ធម្មចក្ខុ ខ្សែ ២២ ទំព័រ ៩៩៧ ។

អាក្រក់គ្មានផ្លូវនឹងកើតឡើងបាន មានតែសេចក្ដីល្អឲ្យបានសេចក្ដីសុខម្យ៉ាងប៉ុណ្ណោះ ។ ធម៌នេះ មានលក្ខណៈនឹងកិច្ចផ្សេងអំពីសីល, សីលមានការរៀបរយកាយវាចាជាលក្ខណៈ មានការកំចាត់បង់សេចក្ដីអាក្រក់ ដែលនឹងគប្បីប្រព្រឹត្តកន្លងដោយកាយវាចាជាកិច្ច រមែងសម្រេចជាសីលបានដោយការលះវៀរ គឺលះវៀរតាមសិក្ខាបទនោះៗ ។ ចំណែកធម៌នោះ មានសភាពទ្រទ្រង់អ្នកប្រព្រឹត្តកុំមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់, មានកិរិយាធ្វើអធ្យាស្រ័យរបស់មនុស្សអ្នកប្រព្រឹត្តឲ្យរឹតតែល្អិតសុខុមក្រៃលែង ជាងភាពដើមជាលក្ខណៈ, មានការកំចាត់បង់សេចក្ដីអាក្រក់ ដែលនឹងគប្បីកើតឡើងក្នុងចិត្តជាកិច្ច រមែងសម្រេចប្រយោជន៍ដល់អ្នកប្រតិបត្តិបានដោយការធ្វើតាមសីលនឹងធម៌ មានលក្ខណៈនឹងកិច្ចផ្សេងគ្នាដូច្នេះ ហេតុនោះ ទើបបាត់ថាជាខប្រតិបត្តិដែលបុគ្គលនឹងត្រូវបំពេញឲ្យប្រព្រឹត្តទៅទាំង ២ យ៉ាង នឹងបំពេញតែមួយៗ មិនបានទេ ។ កំបុគ្គលអ្នករក្សាសីល ឈ្មោះថា ជាអ្នកវៀរចាកសេចក្ដីអាក្រក់បានមែនហើយ ប៉ុន្តែសេចក្ដីអាក្រក់ដែលលះវៀរបានដោយសីលនោះ ជាសេចក្ដីអាក្រក់យ៉ាងគ្រោតគ្រាតដែលឃើញបានងាយ ចំណែកសេចក្ដីអាក្រក់យ៉ាងល្អិតនៅមានក្នុងចិត្តទៀត ប្ដូនឹងគប្បីកើតឡើងផ្លូវចិត្តផុតវិស័យរបស់សីលដែលនឹងកំចាត់បាន ។ គប្បីឃើញដូចបុគ្គលអ្នករក្សាសីលតែម្យ៉ាង គ្មានធម៌ជាគ្រឿងគាំពារ បើទៅជួបប្រទះនឹងមនុស្សមានទុក្ខ ដូចឃើញគេធ្លាក់ទឹក

ឬអត់បាយ ហើយដើរហួសទៅមិនបានជួយគេឲ្យផុតពីអន្តរាយផង យ៉ាងនេះសីលមិនដាច់ទេ ប៉ុន្តែជាហេតុឲ្យគេតិះដៀលបានថាជាអ្នកប្រាសចាកមេត្តាករុណាដល់មនុស្សមានទុក្ខវេទនា ព្រោះហេតុនេះ បុគ្គលអ្នករក្សាសីលតែម្យ៉ាងមិនទាន់បានឈ្មោះថាល្អមែនទែនទេ ឬថាមានធម៌មិនទាន់បានទេ ត្រូវតែជាអ្នកប្រតិបត្តិធម៌ផង ទើបបាត់ថាល្អមែនទែន ឬមានធម៌បាន ហើយបានឈ្មោះថាជាអ្នកមានសីលមានធម៌ ។

មួយទៀត អ្នករក្សាសីលដែលនឹងរក្សាឲ្យបរិសុទ្ធបាន ត្រូវតែអាស្រ័យការប្រព្រឹត្តធម៌ឲ្យជាគូគា ។ សីលកាលមានធម៌ជាគ្រឿងអប់រំហើយ នឹងដាច់ធ្លុះធ្លាយដោយកម្រណាស់ រមែងរឹងប៉ឹងមាំមួន ។ សីលដែលនឹងដាច់ធ្លុះធ្លាយទៅបាន ក៏ព្រោះអាស្រ័យចិត្តមានអធ្យាស្រ័យទៅគ្រោតគ្រាត ។ កាលចិត្តបានអាស្រ័យធម៌ជាគ្រឿងអប់រំហើយ រមែងមានអធ្យាស្រ័យល្អិតសុខុម ។ កាលបើចិត្តមានអធ្យាស្រ័យល្អិតសុខុមល្អហើយ សីលនឹងមិនដាច់ទៅដោយងាយៗទេ ហេតុនេះ អ្នករក្សាសីលលោកទើបប្រដៅឲ្យប្រព្រឹត្តធម៌ជាគូគា ។ ធម៌ក្នុងទីនេះ សំដៅយក កល្យាណធម៌ ប្រែថា "ធម៌ដ៏ល្អ" ជាខប្រតិបត្តិដ៏ពិសេស ត្រូវរក្សាឲ្យជាគូនឹងសីលប្រាំ ។ អ្នកដែលមានកល្យាណធម៌នៅក្នុងចិត្ត លោកហៅថា កល្យាណជន ប្រែថា "ជនល្អ" កល្យាណធម៌នោះលោកចែកទុកជា ៥ ប្រការ ជាគូគានឹងសីល ៥ គឺ

១– មេត្តានឹងករុណា គូនឹងសីលសិក្ខាបទទី ១

២– សម្មាអាជីវៈ ,, ២

៣– សេចក្ដីសង្រួមក្នុងកាម ,, ៣

៤– ការមានសត្យ ,, ៤

៥– ការមានសតិជុំវិញ ,, ៥

## អធិប្បាយ

១— មេត្តា បានដល់ការផ្សាយមេត្រីចិត្ត គិតប្រាថ្នាឲ្យគេបានសុខ ៗ ការផ្សាយមេត្តានេះប្រព្រឹត្តទៅដោយអាការ ២ យ៉ាង គឺផ្សាយទៅដោយចំពោះពួកគណៈរបស់ខ្លួន បុគ្គលដែលខ្លួនធ្លាប់ស្គាល់ ហៅថា ឧទ្ទិស្សផរណា ១, ការផ្សាយទៅក្នុងសត្វមិនមានប្រមាណ មិនចំពោះអ្នកណា ទោះបីជាសត្វបុគ្គល មិនកំណត់ពួកនោះពួកនេះ ហៅថា អនោទិស្សផរណា ១ ។

គុណធម៌នេះជារបស់សំខាន់ក្រៃលែងរបស់ពួកមនុស្ស ជាហេតុឲ្យមានសេចក្ដីគោរពរាប់អានគ្នា មានសេចក្ដីអើពើជួយគ្នាទៅវិញទៅមក ផ្សាយមេត្តាទៅដោយចំពោះ ជាហេតុឲ្យមនុស្សដែលខ្លួនផ្សាយមេត្តាទៅដល់នោះមានសេចក្ដីស្រឡាញ់គោរពរាប់អាន គប្បីឃើញដូចយ៉ាងមាតាបិតាមានសេចក្ដីមេត្តាក្នុងបុត្រធីតា ខំស្វាហាប់ទំនុកបម្រុងឲ្យបានទទួលសេចក្ដីសុខជាយ៉ាងក្រៃលែង បុត្រធីតាក៏មានសេចក្ដីស្រឡាញ់គោរព

មាតាបិតានោះយ៉ាងខ្លាំងក្លា បើមាតាបិតាគ្មានមេត្តាក្នុងបុត្រធីតាទេ គ្រាន់តែចិញ្ចឹមកុំឲ្យគេតិះដៀលប៉ុណ្ណោះ បុត្រធីតាក៏មិនសូវមានចិត្តស្រឡាញ់គោរពមាតាបិតាណាស់ដែរ ។

ការផ្សាយមេត្តាដោយមិនចំពោះ ជាហេតុឲ្យមនុស្សទាំងឡាយមានសេចក្តីស្រឡាញ់គោរពរាប់អាន គប្បីឃើញដូចយ៉ាងបុគ្គលដែលមិនធ្លាប់ស្គាល់គ្នាមកពីមុន ប៉ុន្តែលុះបានទទួលសេចក្តីអើពើផ្សាយមេត្តារកគ្នាទៅវិញទៅមកហើយ ត្រឡប់ជាមានសេចក្តីស្រឡាញ់គោរពរាប់អានគ្នា នេះក៏ព្រោះមេត្តា ។ បើអ្នកទាំង ២ ខាងចេះតែមានចិត្តប្រស្សាឈ្នានីសគ្នា ធ្វើម្តេចនឹងស្រឡាញ់គ្នាកើត កុំថាតែមនុស្ស សូម្បីសត្វតិរច្ឆាន កាលបើបានទទួលសេចក្តីពក់ពាក់ទំនុកបំរុងអំពីអ្នកណា ក៏គង់តែចេះសំដែងអាការស្រឡាញ់ពេញចិត្តនឹងអ្នកដែលមានមេត្តាដល់វានោះដែរ ព្រោះដូច្នោះ បានជាលោកប្រដៅឲ្យបំពេញទាន ។ នេះក៏ដើម្បីឲ្យជាការសំដែងមេត្រីចិត្ត ។ មេត្តានេះជាគ្រឿងទំនុកបំរុងសីលសិក្ខាបទទី ១ ឲ្យមាំមួនក្រៃលែងឡើង បើក្នុងកាលខ្លះកើតចិត្តព្យាបាទឈ្លោះប្រកែកគ្នា កាលតាំងចិត្តផ្សាយមេត្តាទៅហើយ គឺតាំងចិត្តឲ្យគិតឃើញថាយើងជាអ្នកស្រឡាញ់សុខ ស្អប់ខ្ពើមទុក្ខ រូបគេក៏ដូចជាយើងដែរ កាលបើយើងធ្វើឲ្យគេមានសេចក្តីក្តៅក្រហាយ គេក៏មុខជាខានបានសុខ យើងមិនគួរនឹងធ្វើឲ្យគេបានទុក្ខទេ លំដាប់នោះក៏នឹងធ្វើចិត្តប្រស្សាឈ្នានីសព្យាបាទ ឲ្យស្រាកស្រាន្តថយចុះបានរហូតដល់លែងព្យាបាទគេជាទីបំផុត ។

ករុណា បានដល់សេចក្ដីអាណិតអាសូរ ប្រាថ្នានឹងឲ្យគេផុតទុក្ខ ក្នុងវេលាអ្នកដទៃបានទទួលទុក្ខ ។ គុណធម៌នេះចាត់ថាជាធម៌ដ៏សំខាន់, ប្រការមួយទៀត សឹងជាហេតុដែលនឹងធ្វើឲ្យមនុស្សគ្រប់ៗរូបមានសេចក្ដីជួយជ្រោមជ្រែងក្នុងរឿងទុក្ខភ័យនៃគ្នានឹងគ្នា មិនអង្គុយស្ងៀមមើលបំណាំគ្នា ។ កាលបើគ្មានករុណាដល់គ្នាទេ គង់តែមានចិត្តអាក់អន់នឹងគ្នាខ្វះមិនខាន, ករុណាជាគ្រឿងដាស់តឿនចិត្តឲ្យគិតដល់សេចក្ដីសុខទុក្ខរបស់អ្នកដែលខ្លួនមិនពេញចិត្ត លំដាប់ពីនោះ ក៏មិនកើតសេចក្ដីអាណិតអាសូរមិនអាចបៀតបៀនគេបាន. ការមិនចូលចិត្ត មិនពេញចិត្តក៏អន់ថយតិចទៅ ដរាបដល់អស់រលីង ។

មេត្តានឹងករុណាទាំង ២ នេះ ជាគ្រឿងកំចាត់វិហឹង្សាវិតក្ក គឺគិតបៀតបៀនអ្នកដទៃ ។ កាលបើមនុស្សយើងចេះតែមានមេត្តាករុណាដល់គ្នានឹងគ្នាដូច្នេះគ្រប់ៗរូបហើយ ការបៀតបៀនប្រទូសរ៉ាយគ្នាក៏លែងកើតមាន, ដូច្នេះ សីលសិក្ខាបទទី ១ ក៏នឹងរឹតតែតាំងមាំមួនខ្លាំងឡើងលើសដើម ។

មេត្តានឹងករុណានេះមានគុណច្រើនដូចពោលមកហើយ ប៉ុន្តែត្រូវប្រើក្នុងផ្លូវដែលត្រូវ បើប្រើក្នុងផ្លូវខុស ដូចជួយអ្នកត្រូវទោសព្រោះប្រព្រឹត្តខុសជាដើម មិនចាត់ជាមេត្តាករុណាទេ ហើយបានឈ្មោះថាទំនុកបម្រុងអ្នកធ្វើខុស, ផ្លូវដែលល្អគួរតែពិចារណាថា ជាកម្មរបស់គេ

ដែលគេបានធ្វើទុកមកហើយ រួចត្រូវតាំងចិត្តឲ្យនៅជាកណ្ដាល; មេត្តានឹងករុណាកាលបើប្រើខុសផ្លូវដូច្នេះ រមែងមានទោសច្រើនដូចគ្នា; នេះចាត់ជាកល្យាណធម៌គួនឹងសីលសិក្ខាបទទី ១ ។

២– សម្មាអាជីវៈ បានដល់សេចក្ដីព្យាយាមស្វែងរកគ្រឿងចិញ្ចឹមជីវិតក្នុងផ្លូវដែលត្រូវ; គុណធម៌នេះចាត់ថាជាធម៌សំខាន់ប្រការមួយរបស់បុគ្គលអ្នករក្សាសីល នឹងចាត់ថាជាគ្រឿងផ្គត់ផ្គង់សីលសិក្ខាបទទី ២ ឲ្យរឹតតែមាំមួនក្រៃលែងឡើង ។ បុគ្គលអ្នករក្សាសីលហើយ បានឈ្មោះថាជាអ្នកលះវៀរចាកការស្វែងរកគ្រឿងចិញ្ចឹមជីវិតក្នុងផ្លូវដែលខុស សូម្បីវៀរចាកការស្វែងរកក្នុងផ្លូវដែលខុសដូច្នោះហើយ ក៏ត្រូវតែខំស្វែងរកក្នុងផ្លូវដែលត្រូវផង (១) បើមិនខំស្វែងរកទេ គ្រឿងចិញ្ចឹមជីវិតរបស់ខ្លួនក៏នឹងខ្វះខាត កាលបើខ្វះគ្រឿងចិញ្ចឹមជីវិតហើយ រាងកាយក៏គង់ទ្រទ្រង់នៅមិនបាន ត្រូវតែស្លាប់ ឬមានអ្នកខ្លះបានអាស្រ័យបរិភោគទ្រព្យសម្បត្តិចាស់ដែលមានស្រាប់ ប៉ុន្តែបើគ្មានទ្រព្យថ្មីចូលសោះ ទ្រព្យចាស់មុខ

---

១ ក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនា សុទ្ធតែប្រដៅមនុស្ស ឲ្យមានព្យាយាមប្រឹងប្រែងទាំងអស់ មិនដែលប្រដៅឲ្យខ្ជិលច្រអូសទេ គឺប្រដៅថា បើជាគ្រហស្ថត្រូវខំធ្វើការចិញ្ចឹមជីវិត ឬខំប្រព្រឹត្តធម៌ឲ្យមែនទែន កុំខ្ជិល កុំធ្វេសប្រហែសឡើយ បើជាភិក្ខុបព្វជិតវិញ ត្រូវតែខំប្រឹងប្រព្រឹត្តធម៌ឲ្យខ្លាំងក្លាលើសគ្រហស្ថទៅទៀត ។ ប៉ុន្តែរឿងនេះ មានអ្នកខ្លះដែលមិនយល់ច្បាស់ក្នុងផ្លូវធម៌របស់ព្រះពុទ្ធសាសនានោះ ត្រឡប់ជាតិះដៀលថា ព្រះពុទ្ធសាសនាប្រដៅឲ្យមនុស្សខ្ជិលច្រអូស អ្នកកាន់ពុទ្ធសាសនាសុទ្ធតែជាមនុស្សទម្រន់ ពួកអ្នកបួសជាមនុស្សខ្ជិលណាស់ ឥតបានការអ្វីសោះ ។ អ្នកមានគំនិតបែបនេះខុសស្រឡះ ព្រោះតែខ្លួនល្ងង់ខ្លៅ ឬខ្លួនមិនធ្លាប់ហែល បានជាហ៊ានថាស្ពានបំពានផ្លូវច្រេះ ។

ជារលស់អស់ទៅកល់ថ្ងៃ រហូតដល់ផុតអស់រលីងឥតសល់អ្វី, បើទ្រព្យចាយអស់រលីងហើយ សេចក្ដីទាល់ក្រចូលមកសង្កត់កយ៉ាងធ្ងន់ ទាល់តែទ្រាំរក្សាសីលតទៅទៀតមិនបាន ទឹងត្រូវបែរក្បាលចុះទៅកាន់ភាពជាមនុស្សចោរកាចម្ដងទៀត ព្រោះហេតុនោះ លោកទើបប្រដៅឲ្យអ្នកដែលតាំងនៅក្នុងសីល ឲ្យមានព្យាយាមខំប្រឹងប្រែងស្វែងរកគ្រឿងចិញ្ចឹមជីវិតកុំឲ្យខ្ជិលច្រអូស ប៉ុន្តែឲ្យស្វែងរកតែក្នុងផ្លូវដែលត្រូវធម៌ដូចយ៉ាងដែលហៅថា សម្មាអាជីវៈ ។ ការស្វែងរកក្នុងផ្លូវត្រូវតាមគន្លងធម៌ក្នុងទីនេះ មិនមែនសំដៅយកតែត្រឹមថា ឲ្យវៀរចាកមិច្ឆាជីវៈប៉ុណ្ណោះទេ កាលបើវៀរចាកមិច្ឆាជីវៈហើយ ត្រូវប្រកបដោយសេចក្ដីប្រព្រឹត្តជាធម៌ក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតផង រឿងនេះគប្បីឃើញសេចក្ដីប្រព្រឹត្តជាធម៌ក្នុងកិច្ចការ ក្នុងបុគ្គល ក្នុងវត្ថុ ដូចតទៅនេះ ៖

**សេចក្ដីប្រព្រឹត្តជាធម៌ក្នុងកិច្ចការៈ** ការងារគ្រប់យ៉ាងដែលខ្លួនត្រូវធ្វើហើយទឹងបានទទួលផលប្រយោជន៍អំពីគេ ត្រូវតែតាំងចិត្តធ្វើឲ្យមែនទែន សំដៅយកផលជាធំ កុំគិតតែចង់បានមួយចំណែក ដូចជាខ្ញុំរាជការបានទទួលផលប្រយោជន៍អំពីរដ្ឋបាល ត្រូវតែតាំងចិត្តធ្វើការឲ្យរដ្ឋបាលមែនទែនរក្សាកិច្ចការជាមុខក្រសួងរបស់ខ្លួនកុំឲ្យខ្វះខាត ធ្វើកិច្ចការនោះៗ ឲ្យសម្រេចទៅដោយល្អ មិនបិទបាំងមុខក្រសួង ធ្វើឲ្យពេញលេញតាមកំណត់កាលវេលា កាលមកធ្វើការ ក៏មកឲ្យត្រឹមត្រូវ

តាមពេល កាលទឹងត្រឡប់ទៅផ្ទះវិញ ក៏ត្រឡប់ឲ្យត្រឹមត្រូវតាមពេល រួមសេចក្ដីថា កុំធ្វើដោយឃើញតែបាន ៗ សូម្បីកិច្ចការយ៉ាងដទៃ ៗ ដែលខ្លួនត្រូវបានទទួលផលប្រយោជន៍អំពីគេ ក៏ត្រូវធ្វើដោយស្មោះត្រង់ កុំយកចំណេញយកប្រៀបគេ ធ្វើឲ្យសមគួរដល់ការដែលទឹងបានទទួលប្រយោជន៍អំពីគេ នេះឈ្មោះថាសេចក្ដីប្រព្រឹត្តជាធម៌ក្នុងកិច្ចការ ។

**សេចក្ដីប្រព្រឹត្តជាធម៌ក្នុងបុគ្គលៈ** ការងារដែលត្រូវធ្វើ សុទ្ធតែជាប់ជំពាក់នឹងមនុស្សទូទៅ ក៏ត្រូវធ្វើឲ្យស្មើ មិនយល់មុខថាអ្នកនោះអ្នកនេះ ដូចជាឈ្មួញ កាលយករបស់មកលក់ត្រូវកំណត់ថា យើងទឹងលក់យកចំណេញប៉ុន្មាន ហើយទើបបានលក់ កាលលក់ក៏ត្រូវលក់ឲ្យស្មើមុខគ្នា ដូចជាលក់ឲ្យអ្នកនេះ ថ្លៃប៉ុណ្ណេះ កាលលក់ឲ្យអ្នកដទៃក៏ឲ្យដំឡៃស្មើគ្នាដែរ ក្នុងរបស់ដូចគ្នា ទោះអ្នកទិញជាមនុស្សជាន់ណាក៏ដោយ ត្រូវលក់ឲ្យដំឡៃស្មើគ្នាជាដរាប មិនត្រូវលក់ឲ្យខុសដំឡៃគ្នាដូច្នេះជាដើម នេះឈ្មោះថាប្រព្រឹត្តជាធម៌ក្នុងបុគ្គល ។

**សេចក្ដីប្រព្រឹត្តជាធម៌ក្នុងវត្ថុៈ** ដូចបុគ្គលដែលជាអ្នកជំនួញនោះ កាលនាំយកទំនិញមកលក់តែងដឹងថា របស់នោះល្អ របស់នោះមិនល្អ កាលលក់ក៏ប្រាប់អ្នកទិញតាមពិត ដូចរបស់សុទ្ធក៏ប្រាប់ថាសុទ្ធ របស់ក្លែងក្លាយក៏ប្រាប់ថាក្លែងក្លាយ របស់ល្អក៏ប្រាប់ថាល្អ

មិនល្អក៏ប្រាប់ថាមិនល្អ ប្រាប់តាមការពិតនៃវត្ថុនោះៗ មិនកុហកបញ្ឆោត ដូចរបស់មិនល្អប្រាប់ថាល្អ របស់ក្លែងក្លាយប្រាប់ថារបស់សុទ្ធជាដើម. នេះឈ្មោះថាសេចក្ដីប្រព្រឹត្តជាធម៌ក្នុងវត្ថុ ។

មួយទៀត អ្នកមានសីល សូម្បីវៀរចាកការងារដែលជាទោស ដោយត្រង់ដូច្នោះហើយ ក៏នៅតែត្រូវលះវៀរការងារបែបខ្លះទៀត ដែលជាផ្លូវខូចខាតចាកទ្រព្យសម្បត្តិ ដូចជាស្វែងរកទ្រព្យក្នុងការភ្នាល់ ។ ល្បែងភ្នាល់ជាការនាំឲ្យខូចកេរ្តិ៍ឈ្មោះ ជួនកាលដេកកើតទុក្ខ ជួនកាលខូចខាតទ្រព្យ ។ ឯទ្រព្យដែលបានមកអំពីការភ្នាល់នោះ មិនគង់ទ្រង់អង្វែងដោយហេតុ២ យ៉ាង គឺ១ បានមកងាយប្រើនតែមិនសូវស្ដាយ ចាយងាយ ទុកមិនគង់, ២ ការចង់បានគ្មានទីបំផុត ទោះបីបានប៉ុន្មានក៏នៅតែមិនគ្រប់គ្រាន់ដែរ ចេះតែចំលេងតទៅទៀត គង់តែមានពេលក្សាត់ចាញ់គេមួយគ្រា ។ ទ្រព្យដែលបានមកដោយងាយដូច្នេះ មានសេចក្ដីស្រឡាញ់មិនដូចទ្រព្យដែលបានមកដោយត្រូវចេញដើមទុន ចេញកំ-ឡាំងទេ ។ ទ្រព្យដែលរកបានមកហើយ ត្រូវចេះរក្សាទុកចាយវាយប្រើប្រាស់ឲ្យជាប្រយោជន៍ គឺទំនុកបម្រុងខ្លួនឯងខ្លះ ទំនុកបម្រុងអ្នកដែលគួរទំនុកបំរុងខ្លះ កាលមានហេតុគួរប្រើទើបប្រើ មិនចេះតែចាយវាយខ្ជះខ្ជាយទាល់តែហួសប្រមាណ នឹងមិនត្បិតត្បៀតខ្វាំងពេក ។

មនុស្សគ្រប់រូប កាលបើនាំគ្នាប្រកបការងារដ៏ប្រាសចាកទោស

ប្រកបតែក្នុងផ្លូវត្រូវដូចពោលមកនេះហើយ រមែងបានទទួលសេចក្ដីសុខសប្បាយ មិនត្រូវមានភ័យមានពៀរនឹងអ្នកណាឡើយ ។

សម្រាប់អ្នករក្សាសីល កាលតាំងនៅក្នុងសម្មាអាជីវៈដូច្នេះហើយ រមែងជាផ្លូវដែលនឹងឲ្យរក្សាសីលសិក្ខាបទទី ២ បានបរិសុទ្ធ សីលរបស់ខ្លួនក៏នឹងមិនពពាលមិនពព្រុះ ព្រោះហេតុនោះ គុណធម៌នេះលោកទើបចាត់ថាជាកល្យាណធម៌ប្រការមួយ សម្រាប់បំពេញឲ្យជាគ្នាទៅនឹងសិក្ខាបទទី ២ ។

៣.— សេចក្ដីសង្រួមក្នុងកាម បានដល់កិរិយាដែលមិនប្រ-ព្រឹត្តល្មោកក្នុងកាម ធ្វើសេចក្ដីត្រេកអរក្នុងកាមតាមប្រមាណដែលមាន; គុណធម៌នេះចាត់ថា ជារបស់សំខាន់ក្នុងកិរិយានឹងតាំពារសីលសិក្ខាបទទី ៣ ឲ្យគង់ស្ថិតស្ថេរ នឹងជាគ្រឿងបង្អុលបង្ហាញសេចក្ដីបរិសុទ្ធិរបស់បុរសស្ត្រីឲ្យឃើញច្បាស់ ។ អ្នកដែលលះវៀរចាកកាមហើយ ប៉ុន្តែនៅប្រព្រឹត្តខ្លួនឲ្យជាមនុស្សរវិលរវល់ឈ្លក់នៅក្នុងកាម ក៏ត្រូវចាត់ថាជាអ្នកមានមន្ទិល មិនមែនជាអ្នកបរិសុទ្ធស្អាត ។

សម្រាប់បុរស កាលមានភរិយាហើយ ក៏ត្រេកអរពេញចិត្តនៅតែក្នុងភរិយារបស់ខ្លួន មិនគួរនឹងទៅស្ម័គ្រស្មោះលបស្រឡាញ់ស្រីដទៃឡើយ កាលបើខ្លួនមានប្រពន្ធហើយយ៉ាងណា ក៏គប្បីតាំងសេចក្ដីឧស្សាហ៍ចិញ្ចឹមរក្សាគ្នាទៅ បើទុកជាក្រលំបាកយ៉ាងណាក៏មិនត្រូវលះ

បង់ពេលគ្នាដែរ នេះឈ្មោះថាជាអ្នកកាន់នៅគុណ សទារសន្តោស ប្រែថា "ត្រេកអរតែក្នុងភរិយារបស់ខ្លួន," អ្នកប្រតិបត្តិខ្លួនបានដូច្នេះ រមែងជាទីគួរសរសើរ ទាំងជាទីស្រឡាញ់ទុកចិត្តរបស់អ្នកដទៃផង ។

សម្រាប់ស្ត្រី កាលមានស្វាមីហើយ ក៏ត្រេកអរនៅតែក្នុងស្វាមីរបស់ខ្លួន តាំងចិត្តទំនុកបម្រុងបំរើស្វាមីរបស់ខ្លួនមិនទៅស្ម័គ្រស្មោះរួមរក្សស្រឡាញ់ប្រុសដទៃ សូម្បីស្វាមីរបស់ខ្លួនមានសេចក្តីទាល់ក្រលំបាកយ៉ាងណាក៏ដោយ មិនសំដែងអាការព្រងើយកន្តើយសោះអង្គើយទៀយណាយរសាយចិត្តចេញពីស្វាមីរបស់ខ្លួនដែរ ស្ត្រីដូច្នេះ បានឈ្មោះថាមានសេចក្តីប្រព្រឹត្តិធម៌ដ៏ល្អប្រពៃក្នុងស្វាមីរបស់ខ្លួន រមែងជាទីទុកចិត្តរបស់ស្វាមី នឹងជាទីសរសើររបស់ជនទូទៅ ។

មួយទៀត ប្រុសដែលមានភរិយារួចហើយ ឬក៏នៅលីវមិនទាន់មានប្រពន្ធទេ ដែលទៅគប់ប្រសព្វនឹងស្រីដទៃមានស្រីពេស្យាជាដើម សូម្បីមិនចាត់ថាជាកាមេសុមិច្ឆាចារ ក៏នៅតែជាហេតុឲ្យបានទទួលសេចក្តីវិនាសច្រើនប្រការ គឺ៖

ក)– ត្រូវបង់ទ្រព្យ ព្រោះការទំនុកបម្រុងស្រីនោះ តាំងពីត្រូវចាយវាយក្នុងការបណ្តើរគ្នាលេង នឹងបរិភោគដេកអង្គុយរហូតទៅ ដែលជាការមិនគួរឲ្យខូចខាតទ្រព្យ ។

ខ)– ជាអណ្តូងកើតនៃរោគ, បណ្តារោគទាំងអស់ រោគដែល

កើតអំពីស្រីពេស្យា ដែលហៅថា "កាមរោគ" នេះរាប់ថាជារោគយ៉ាងកាចអាក្រក់ម្យ៉ាង អាចធ្វើឲ្យអវយវៈរាងកាយពិកលពិការទៅបាន ក្នុងទីបំផុតក៏ដល់ស្លាប់ បើមិនស្លាប់ទេ រោគនេះក៏អាចជាប់ចូលទៅដល់ភរិយានិងបុត្ររបស់ខ្លួន ធ្វើឲ្យភរិយានិងបុត្ររបស់ខ្លួនបានទទួលទុក្ខជាមួយផង ។

គ)— ជិតជិតនឹងអន្តរាយណាស់, ធម្មតាស្រីពេស្យាតែងតែស្នេហ៍ស្និទ្ធស្រឡាញ់ប្រុសច្រើននាក់ កាលបើប្រុសកើតមានសេចក្តីហឹង្សាប្រជែងគ្នាហើយ ក៏នឹងកើតឈ្លោះវិវាទគ្នាខ្លះ ប្រទូសរ៉ាយរាងកាយគ្នាខ្លះ ។

សម្រាប់ស្ត្រីគ្មានស្វាមី ក៏មិនគួរទៅចងពន្ធស្រឡាញ់បុរស សូម្បីជាប្រុសដែលមិនត្រូវហាមប្រាមក៏មិនគួរដែរ ព្រោះជាទីខូចកេរ្តិ៍ឈ្មោះនិងអាចឲ្យខូចខាតទ្រព្យសម្បត្តិព្រោះការចិញ្ចឹមប្រុស ។

ទោសដែលពោលមកនេះ អាស្រ័យសេចក្តីមិនសង្រួមក្នុងកាមជាហេតុ ព្រោះដូច្នោះ លោកទើបប្រដៅឲ្យសង្រួមក្នុងកាម; កាលបើមានសេចក្តីសង្រួមក្នុងកាមហើយ ការរក្សាសីលក្នុងសិក្ខាបទទី ៣ ក៏នឹងតាំងនៅបានដោយមាំមួន ហេតុនេះ សទារសន្តោស លោកទើបចាត់ជាកល្យាណធម៌ប្រការមួយ ឲ្យបំពេញជាគូគ្នានឹងសីលសិក្ខាបទទី ៣ ។

៤— សេចក្តីមានសត្យ: ការប្រព្រឹត្តិខ្លួនជាមនុស្សត្រង់ ហៅថាមានសត្យ ចាត់ជាគុណធម៌ដ៏សំខាន់ប្រការមួយ ដែលជាគ្រឿងផ្គត់ផ្គង់

សីលសិក្ខាបទទី ៤ ឲ្យមាំមួនស្ថិតស្ថេរ មានប្រភេទដែលទឹងគប្បីវិភាគបានដូចតទៅនេះ ៖

ក)– សេចក្ដីទៀងក្នុងធម៌ បានដល់សេចក្ដីប្រព្រឹត្តខ្លួនជាធម៌ក្នុងកិច្ចការដ៏ជានាទីរបស់ខ្លួន កាលទឹងធ្វើអ្វីមិនធ្វើឲ្យខុសដោយអំណាចអគតិ ៤ គឺ ឆន្ទាគតិ សេចក្ដីលំអៀងព្រោះស្រឡាញ់ ទោសាគតិ សេចក្ដីលំអៀងព្រោះមិនត្រូវគ្នាស្អប់គ្នា មោហាគតិ សេចក្ដីលំអៀងព្រោះល្ងង់ខ្លៅ ភយាគតិ សេចក្ដីលំអៀងព្រោះខ្លាច ។

គប្បីឃើញដូចអ្នកវិនិច្ឆ័យកាត់ក្ដី ដាក់ខ្លួនជាកណ្ដាល កាត់សេចក្ដីទៅដោយធម៌ មិនទន់ទៅចូលខាងពួកដែលខ្លួនស្រឡាញ់ មិនសង្កត់សង្កិនខាងពួកដែលខ្លួនស្អប់ បានដឹងហេតុផលល្អហើយទើបកាត់សេចក្ដី ទឹងមិនខ្លាចផ្លូវខាងនោះខាងនេះ ឬសូម្បីមនុស្សដទៃ ៗ ក៏ប្រកាន់យកតែសេចក្ដីត្រឹមត្រូវជាធំ ។

ខ)– សេចក្ដីស្មោះត្រង់ បានដល់សេចក្ដីប្រព្រឹត្តត្រង់ចំពោះបុគ្គលជាមិត្ត ឬសូម្បីដល់អ្នកដទៃ ៗ គប្បីឃើញតួយ៉ាងក្នុងមិត្តអ្នកវៀរចាកទោស ៤ ស្ថាន គឺមនុស្សគិតតែប្រយោជន៍ខ្លួន, មនុស្សល្អតែមាត់, មនុស្សប្រចុប, មនុស្សដឹកនាំក្នុងផ្លូវវិនាស, ហើយជាអ្នកប្រកបដោយភាពជាមនុស្សមានឧបការ, មនុស្សរួមសុខរួមទុក្ខ, មនុស្សប្រាប់ប្រយោជន៍មិត្ត ដូច្នេះបានឈ្មោះថាស្មោះត្រង់ចំពោះមិត្ត ។

គ)— ស្វាមីភក្តិ បានដល់សេចក្ដីស្រឡាញ់ភក្ដីក្នុងចៅហ្វាយនាយរបស់ខ្លួន កាលបើខ្លួនព្រមលើកឲ្យអ្នកណាធ្វើជាចៅហ្វាយនាយរបស់ខ្លួនហើយ ខ្លួនក៏តាំងចិត្តប្រព្រឹត្តស្មោះត្រង់សុចរិត មិនគិតទុយ៌ស ចំពោះបុគ្គលនោះ ចាំជួយមើល នឹងជាកំឡាំងក្នុងកិច្ចតូចធំទាំងពួង ហេតុដល់ជួយការពាររវាំងសេចក្ដីអាក្រក់វិនាស មិនឲ្យកើតឡើងដល់ចៅហ្វាយនាយរបស់ខ្លួន ក្នុងទីបំផុត សូម្បីជីវិតក៏អាចលះបង់ជួសបាន មានចិត្តស្រឡាញ់ភក្ដីជានិច្ចមិនបែកចិត្ត នេះបានឈ្មោះថាជាអ្នកស្វាមីភក្ដិ ។

ឃ)— សេចក្ដីកតញ្ញូ បានដល់សេចក្ដីដឹងឧបការៈដែលលោកបានធ្វើហើយដល់ខ្លួន ជាគុណនឹងកតវេទី ដែលថា អ្នកដឹងឧបការៈដែលលោកធ្វើហើយ នឹងធ្វើតបវិញ តែក្នុងទីនេះមិនបានប្រាថ្នាយ៉ាងនោះ ប្រាថ្នាតែត្រឹមមិនភ្លេចគុណរបស់លោក ដូចខ្លួនបានទទួលឧបការគុណអំពីលោកអ្នកដទៃដូចមាតាបិតាជាដើម ក៏មិនភ្លេចគុណរបស់លោកដែលបានធ្វើឧបការៈឲ្យខ្លួនដាក់លោកទុកក្នុងឋានៈដែលជាអ្នកមានគុណ មានសេចក្ដីគោរពរាប់អានលោក មិនជាមនុស្សលុបគុណរបស់លោក ។

ព្រោះដូច្នោះ សេចក្ដីមានសត្យ ទើបចាត់ថាជាគុណធម៌ដ៏សំខាន់ក្រៃលែងក្នុងការដែលនឹងទំនុកបម្រុងសីលសិក្ខាបទទី ៤ ឲ្យមាំមួនឡើង ៗ កាលបើមិនមានសេចក្ដីសត្យសុចរិតទេ សីលនេះក៏នឹងបែកធ្លាយទៅបាន

ដោយងាយ ហេតុនោះ សេចក្ដីមានសត្យ លោកទើបចាត់ជាកល្យាណ-ធម៌ប្រការមួយ សម្រាប់បំពេញជាគុណនៃសីលសិក្ខាបទទី ៤ ។

៥– សេចក្ដីមានសតិជុំវិញ បានដល់សេចក្ដីមិនភ្លេចភ្លាំង មិនភ្លេចស្មារតី កាលនឹងធ្វើកិច្ចការអ្វីៗ ក៏ឲ្យមានសតិសម្បជញ្ញៈចាំត្រិតត្រា រកំរងប្រយ័ត្នមិនឲ្យខុសក្ដាត់ ។ គុណធម៌នេះ រាប់ថាជាកិច្ចសំខាន់ប្រការមួយ ដែលនឹងផ្គត់ផ្គង់សីលទុកឲ្យមាំមួន ។ សីលគ្រប់ៗដែលនឹងដាច់ធ្លុះធ្លាយទៅបាន ក៏ព្រោះភាពជាអ្នកមិនមានសតិសម្បជញ្ញៈចាំពិនិត្យពិចារណា ។ អ្នកដែលប្រើសតិសម្បជញ្ញៈប្រចាំការ នឹងធ្វើអ្វីក៏មិនខុសមិនភ្លាំងភ្លាត់ ព្រោះដូច្នោះ ភាពជាអ្នកមានសតិជុំវិញ លោកទើបចាត់ថាជាធម៌ផ្គត់ផ្គង់សីលឲ្យមាំមួន មានប្រភេទដែលនឹងលើកឡើងពោលក្នុងទីនេះ ៤ ប្រការ ៖

(ក– សេចក្ដីស្គាល់ប្រមាណក្នុងអាហារដែលនឹងបរិភោគៈ អាហារនោះតាមធម្មតាក៏មានប្រយោជន៍ដល់រាងកាយ ធ្វើឲ្យរាងកាយគង់ទ្រង់នៅបាន បើមនុស្សយើងមិនបានអាស្រ័យអាហារទេ ជាតិរាងកាយក៏គង់ទ្រង់នៅមិនបាន តាមធម្មតាជាយ៉ាងនេះក៏មែនហើយ ប៉ុន្តែសូម្បីដូច្នោះក៏ត្រូវតែអាស្រ័យភាពជាអ្នកដឹងប្រមាណ បរិភោគតែល្មមសមគួរ បើមិនដូច្នោះទេ អាហារនោះឯងនឹងក្លាយទៅជាទោសវិញ ហេតុនេះគប្បីវៀរចាករបស់ដែលដូចម្ដេច ដែលនឹងកឲ្យកើតទោស មិនបរិភោគឲ្យ

ច្រើនពេកឬខ្សត់ពេក ឲ្យពិចារណាមើលថា អាហារណាជាទោសដល់រាងកាយ អាហារណាជាប្រយោជន៍ វៀរចាកអាហារដែលជាទោស បរិភោគតែអាហារដែលមានប្រយោជន៍ ។ បើមិនមានសេចក្ដីដឹងស្គាល់ប្រមាណទេឲ្យតែឃើញអាហារក៏ចេះតែបរិភោគទៅដូច្នេះ រមែងជាទោសគឲ្យកើតសេចក្ដីទុក្ខលំបាកដល់រាងកាយបានក្នុងពេលខ្លះ ព្រោះដូច្នោះលោកទើបប្រដៅឲ្យដឹងស្គាល់ប្រមាណក្នុងអាហារ ។

១)— សេចក្ដីមិនធ្វេសប្រហែសក្នុងការងារ : បានដល់កិរិយាដែលមិនព្រងើយកន្ដើយ បណ្ដែតបណ្ដោយលះចោលធុរៈក្នុងកិច្ចការងារដែលខ្លួនត្រូវធ្វើឲ្យខ្ចប់ខ្ចួត ប្រញាប់ចាត់ចែងប្រញាប់ធ្វើឲ្យរួចស្រេច និងធ្វើឲ្យត្រូវតាមកាលៈទេសៈ គប្បីឃើញដូចយ៉ាងធ្វើស្រែចម្ការ និងត្រូវតែប្រញាប់ចាត់ចែងធ្វើឲ្យត្រូវតាមរដូវកាល បើបង្អង់ទុកទៅធ្វើក្នុងវេលាមិនមែនរដូវកាល ក៏ឥតបានផល ។ សូម្បីការលក់ដូរជួញប្រែក៏ត្រូវតែពិចារណាឲ្យសមគួរតាមកាល ត្រូវគិតទុកជាមុនថារបស់លក់វេលានោះវេលានេះនឹងបានថ្លៃច្រើនឬតិច – របស់ណាមានមនុស្សត្រូវការច្រើន របស់ណាមិនសូវមានគេត្រូវការចង់បាន, បើជាកិច្ចការរឹតតែល្អិតសំខាន់ឡើង ក៏ត្រូវតែខំពិចារណាឲ្យច្រើនដែរ ដូចធ្វើរាជការ ត្រូវតែជាអ្នកចេះដឹងយល់ច្បាស់ក្នុងវិធីដំណើរការ ប្រុងប្រយ័ត្នឲ្យច្រើនណាស់ និងត្រូវតែរក្សារបៀបទុកមិនឲ្យភ្លាំងភ្លាត់; អ្នកដែលមានសេចក្ដីប្រយ័ត្នដូច្នេះ ឈ្មោះថាមិនធ្វេសប្រហែសក្នុងកិច្ចការ ។

គ)– សេចក្ដីមានសម្បជញ្ញៈក្នុងការប្រព្រឹត្តខ្លួន: បានដល់កិរិយាដែលដឹងជុំវិញ ក្នុងការដែលខ្លួននឹងធ្វើ នឹងនិយាយ នឹងគិត ប្រុងប្រយ័ត្នមិនឲ្យភ្លាំងភ្លាត់ នឹងធ្វើ នឹងនិយាយ នឹងគិត ក៏រំពឹងគិតពិចារណាមើលមុខមើលក្រោយ ផ្លូវបានផ្លូវបង់ឲ្យរៀបរយសព្វគ្រប់ កាលបើដឹងថា យ៉ាងណា នឹងជាគ្រឿងវិនាសជាផ្លូវឲ្យកើតទោស ក៏វៀរចេញ ប្រកបតែផ្លូវដែលមានគុណ ដូច្នេះ រមែងជាបច្ច័យឲ្យធ្វើការអ្វីៗ មិនភ្លាត់ខុស នេះឈ្មោះថាសេចក្ដីមានសម្បជញ្ញៈក្នុងការប្រព្រឹត្តខ្លួន ។

ឃ)– សេចក្ដីមិនប្រមាទក្នុងធម៌: បានដល់សេចក្ដីញុំាងបញ្ញាចុះពិចារណាឲ្យឃើញតាមសភាពសេចក្ដីកើតពិតរបស់សង្ខារថា មនុស្សយើងដែលកើតមកក្នុងលោកនេះ រមែងត្រូវមានសេចក្ដីចាស់ឈឺស្លាប់ជាធម្មតា ជាយ៉ាងនេះស្មើគ្នាទាំងអស់ ផ្សេងគ្នាតែត្រង់ឆាប់ឬយូរប៉ុណ្ណោះទេ ។ កាលបើឃើញតាមកើតពិតហើយ មិនធ្វើខ្លួនឲ្យជាមនុស្សម្លូម៉ៅ ស្រវឹងជាប់នៅក្នុងសេចក្ដីសុខដែលមានប្រមាណតិច ប្រញាប់ប្រញាល់ធ្វើសេចក្ដីល្អប្រពៃ ធ្វើខ្លួនឲ្យជាប្រយោជន៍ដល់ខ្លួនដល់អ្នកដទៃ ឲ្យសមគ្នានឹងភាពជាអ្នកដែលរស់នៅអាស្រ័យលោក កាលយល់ឃើញថាកិច្ចណា ធ្វើមិនទាន់បានសម្រេច ឬមិនទាន់ធ្វើនៅឡើយ ក៏ខំប្រញាប់ចាត់ចែងធ្វើកិច្ចនោះឲ្យរួចស្រេចទៅ កាលវេលាសេចក្ដីស្លាប់នឹងមានមកដល់ ក៏នឹងមិនបាននឹកស្ដាយក្រោយថា ការយ៉ាងនោះយ៉ាងនេះយើង

មិនទាន់បានធ្វើ បើបានធ្វើរួចស្រេចហើយ សូម្បីនឹករលឹកឃើញក្នុងវេលាណា ក៏រមែងបានទទួលសេចក្ដីរីករាយក្នុងកិច្ចការដែលខ្លួនបានចាត់ចែងធ្វើឲ្យស្រេចហើយនោះ ។

មួយទៀត សេចក្ដីល្អនឹងសេចក្ដីអាក្រក់ ជារបស់ដែលមនុស្សគ្រប់រូបមិនគួរប្រមាទ ព្រោះធម៌ទាំង ២ នេះឲ្យផលមិនស្មើគ្នាទេ សេចក្ដីល្អឲ្យផលជាសុខ សេចក្ដីអាក្រក់ឲ្យផលជាទុក្ខ សេចក្ដីល្អជារបស់ដែលមនុស្សគ្រប់រូបគួរប្រញាប់បំពេញ សេចក្ដីអាក្រក់ជារបស់ដែលគួរវៀរជាដាច់ខាត, សូម្បីសេចក្ដីអាក្រក់ ខ្លួននឹងធ្វើតែត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ក៏មិនគួរធ្វើដែរ ការធ្វើបន្តិចម្ដងៗនោះឯង នឹងជាហេតុឲ្យច្រើនឡើងបានៗ សេចក្ដីល្អនោះឯងគួរតែព្យាយាមធ្វើឲ្យច្រើនឡើង ប៉ុន្តែ បណ្ដាសេចក្ដីល្អនឹងសេចក្ដីអាក្រក់ទាំង ២ នេះ សេចក្ដីល្អច្រើនតែធ្វើបានក្រជាងសេចក្ដីអាក្រក់ ត្រូវតែអាស្រ័យសេចក្ដីព្យាយាមខំប្រឹងធ្វើ សូម្បីខាងដើមមិនចូលចិត្តចង់ធ្វើសោះ ក៏ត្រូវតែខំប្រឹងទំទាញចិត្តឲ្យវាល់តែមានអធ្យាស្រ័យថ្នឹកឬជាប់ស៊ាំ ឯសេចក្ដីល្អដែលបានធ្វើឲ្យកើតមានឡើងក្នុងខ្លួនហើយ សេចក្ដីល្អនោះរមែងនឹងជាទីពឹងរបស់ខ្លួនបាន ទាំងក្នុងបច្ចុប្បន្ននឹងកពមុខ; កាលបុគ្គលបានប្រតិបត្តិខ្លួនឲ្យដំណើរទៅតាមធម៌ ដែលពោលមកនេះហើយ ឈ្មោះថាជាអ្នកមិនប្រមាទក្នុងធម៌ ។

ការមានសតិជុំវិញនេះ កាលមាននៅក្នុងខ្លួនហើយ រមែងនឹងជាបច្ច័យឲ្យតាំងខ្លួនទុកក្នុងគុណធម៌ដែលល្អ នឹងធ្វើ នឹងនិយាយ នឹងគិត

មិនខុស មិនក្លាត់ ចាត់ថាជាគ្រឿងប្រដាប់របស់អ្នកមានសីល ធ្វើឲ្យសីលដែលខ្លួនរក្សារឹតតែមាំមួនក្រៃលែងឡើង លោកទើបចាត់សតិថាជាកល្យាណធម៌ប្រការមួយ សម្រាប់បំពេញជាគូនឹងសីលសិក្ខាបទទី ៥ ។

កល្យាណធម៌ ៥ ប្រការដូចពោលមកនេះ សូម្បីតែ ១ ប្រការក៏រមែងជាគ្រឿងទំនុកបម្រុងសីលឲ្យមាំមួនបានដែរ ប្រៀបដូចសួលដែកដែលនៅក្នុងសសរស៊ីម៉ងត៍ រមែងធ្វើឲ្យសសរនោះរឹងប៉ឹងមាំទាំខ្លាំងឡើងទៀត ហេតុនោះ មនុស្សគ្រប់រូបគួរតែបំពេញធម៌ទាំង ៥ ប្រការនេះឲ្យជាគូគ្នាទៅនឹងសីលជាប់ជានិច្ចចុះ ។

## គោលដែលត្រូវចាំគ្នាង់សីលនឹងធម៌

| សីលសិក្ខាបទ ៥ | | កល្យាណធម៌ ៥ |
|---|---|---|
| ១- បាណាតិបាត | ជាគូនឹង | មេត្តា, ករុណា |
| ២- អទិន្នាទាន | -និ- | សម្មាអាជីវៈ |
| ៣- កាមេសុមិច្ឆាចារ | -និ- | សទារសន្តោស |
| ៤- មុសាវាទ | -និ- | សច្ច |
| ៥- សុរាមេរយ | -និ- | សតិ |

ចប់

### បញ្ញាសជាតក

### ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ជាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## ទុលកបណ្ឌិតទី ១១

លោកអាចារ្យ ឈឹម-ណាក ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

(ត-ចប់)

ហៃកូនជាទីស្រឡាញ់ពេញចិត្តម្ដាយ! ហៃកូនជាទីស្រឡាញ់ស្មើហឫទ័យម្ដាយ! ហៃកូនជាទីស្រឡាញ់ស្មើជីវិតមាសម្ដាយ! តាំងពីដើមរហូតមកទល់នឹងកាលឥឡូវនេះ កូនមិនដែលបានសេចក្ដីលំបាកវេទនាសោះ ម្ដេចឡើយក៏កូនប្រុសមកស្លាប់អសារឥតការយ៉ាងនេះ? បើតែដូច្នេះ សមម្ដាយនឹងបែកទ្រូងស្លាប់ពុំខាន, ចូរកូនកល្យាណអ្នកត្រឡប់ទៅវិញឲ្យឆាប់ៗ ។

ពោធិសត្វជម្រាបមាតាវិញថា បពិត្រព្រះមេមានគុណធ្ងន់! សូមលោកកុំមានប្រសាសន៍យ៉ាងនេះឡើយ, ដ្បិតខ្ញុំបាទ លះជីវិតចំពោះព្រះ

ពុទ្ធ ព្រះធម៌ ព្រះសង្ឃ, សូមលោកកុំហាមឃាត់ខ្ញុំបាទឡើយ; បានជាខ្ញុំនិយាយយ៉ាងនេះ ព្រោះថា

ពុទ្ធោ តិលោកទីបោវរ ពុទ្ធោ សុរិយោ តមោនុទោ
យេ យន្តិ សរណំ ពុទ្ធំ នត្ថិ តេសំ ភយំ សទា ។
ធម្មោ តិលោកទីបោវរ ធម្មោ សុរិយោ តមោនុទោ
យេ យន្តិ សរណំ ធម្មំ នត្ថិ តេសំ ភយំ សទា ។
សង្ឃោ តិលោកទីបោវរ សង្ឃោ សុរិយោ តមោនុទោ
យេ យន្តិ សរណំ សង្ឃំ នត្ថិ តេសំ ភយំ សទា ។
យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
អបទីបោ ន ភវេយ្យ អធិគច្ឆេយ្យ បទំ សុខំ ។

ព្រះសម្មាសម្ពុទ្ធជាប្រទីបក្នុងត្រៃលោក ព្រះអង្គដូចជាព្រះអាទិត្យអាចកំចាត់បង់នូវងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណាបានដល់ព្រះពុទ្ធជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសព្វ ៗ កាល ។ ព្រះសទ្ធម្មជាប្រទីបក្នុងត្រៃលោក, ព្រះសទ្ធម្មនោះឯង ជាព្រះអាទិត្យអាចកំចាត់បង់នូវសេចក្ដីងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណា បានដល់នូវព្រះសទ្ធម្មជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំង-

ឡាយនោះសព្វ ៗ កាល ៗ ព្រះសង្ឃជាប្រទីបក្នុងត្រៃលោក ព្រះសង្ឃនោះឯងជាព្រះអាទិត្យ អាចកំចាត់បង់នូវងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណា បានដល់នូវព្រះសង្ឃជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសព្វ ៗ កាល ៗ បើនរណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹកហើយ, នរជននោះ ឈ្មោះថាជាអ្នកមានប្រទីបគឺបញ្ញា ហើយបាននូវព្រះនិព្វានជាបរមសុខដ៏ក្រៃលែង ៗ

ដោយហេតុនេះហើយ សូមអ្នកម្ដាយកុំឃាត់ខ្ញុំបាទឡើយ ៗ

លំដាប់នោះ មាតារបស់ទុលកបណ្ឌិត កាលបើមិនអាចឲ្យកូនត្រឡប់ទៅវិញបាន ក៏វិលទៅកាន់គេហដ្ឋានវិញទៅ ៗ ទើបទុលកបណ្ឌិតស្ទាបអង្អែលឈើអណ្ដាតនិយាយថា ម្នាលឈើអណ្ដាតអើយ, ឈើដទៃខ្លះគេយកទៅធ្វើជាព្រះវិហារ ឈើខ្លះគេយកទៅរចនាជាព្រះពុទ្ធរូប ឈើខ្លះគេយកទៅធ្វើជាទីបង្ក្រម ឈើខ្លះគេយកទៅធ្វើជាទីអាវាស, ចុះថ្វីកអ្វីតែអ្នកឯងក៏ប្រឡាក់ប្រឡូសមិនស្អាតសោះដូច្នេះ ៗ ខណៈនោះឯងទេវតាបានឮពាក្យពោធិសត្វហើយ ក៏ចុះមកប្រជុំគ្នា ៗ ឈើអណ្ដាតក៏ដួលចុះទៅ ដោយអានុភាពនៃទេវតា ៗ ពួកអ្នកនគរទាំងអស់ក៏ផ្អើលគោឡោឡើង ៗ

ថ្ងៃនោះ បិតាព្រះពោធិសត្វឈ្មោះសុជាតព្រាហ្មណ៍ បានផ្ទុកមាសពេញសំពៅមកអំពីក្រុងបាតលិបុត្ត បានមកដល់ចិននគរហើយ ពួក

មហាជនទាំងអស់ ក៏នាំគ្នាទៅជំរាបគាត់ថា បពិត្រលោកសុជាតដ៏ចំរើន, លោកជ្រាបដែរឬ? លោកឃើញដែរឬ? ទូលកបណ្ឌិតជាបុត្ររបស់លោក ស៊ូលះបង់ជីវិតចំពោះព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ឥឡូវនេះពួកពេជ្ឈឃាតឲ្យឡើងលើឈើអណ្តោតទៅហើយ ។ សុជាតព្រាហ្មណ៍បានឮពាក្យនោះហើយ ក៏មានដួងហឫទ័យញាប់ញ័រ ស្តុកក្តៅក្រហាយសព្វសព៌ាង្គកាយ ហើយមកប្រញាប់ប្រញាល់ តំរង់ទៅព្រៃស្មសាន; លុះទៅដល់ហើយឃើញកូនដូច្នោះ ក៏និយាយនឹងពួកពេជ្ឈឃាតថា "ម្នាលពួកពេជ្ឈឃាត, អ្នកកុំធ្វើកូនខ្ញុំឲ្យវិនាសឡើយ ខ្ញុំនឹងលោះយកវិញ" ហើយគាត់ទៅកាន់ព្រះលានស្តេច ក្រាបបង្គំទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព, សូមទ្រង់ព្រះមេត្តាប្រោសសង្គ្រោះទូលព្រះបង្គំជាខ្ញុំ, សូមព្រះអង្គកុំឲ្យបុត្រទូលព្រះបង្គំជាខ្ញុំវិនាសឡើយ, ទូលព្រះបង្គំជាខ្ញុំនឹងលោះយកកូននេះវិញ" ។ ព្រះរាជា បានទ្រង់ព្រះសវនាការពាក្យព្រាហ្មណ៍ក្រាបបង្គំទូលដូច្នោះហើយត្រាស់ថា "ម្នាលព្រាហ្មណ៍ លុះតែអ្នកឯងឲ្យមាសប៉ុនសរីរៈកូនអ្នកឯងមកយើង ទើបយើងឲ្យកូននោះរួចបាន" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំស៊ូតែថ្វាយ កុំឲ្យខ្វះកន្ទះឡើយ" ហើយទៅបើកសំពៅយកមាសមកដំកល់ទុកប៉ុនសរីរៈកូនលោះយកកូន នាំយកទៅផ្ទះវិញ ។

គ្រានោះ ព្រះសង្ឃត្ថេរ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលលោកដ៏មានអាយុទាំងឡាយ, យើងទាំងឡាយដែលរួចចាកទុក្ខព្រោះតែ

ទុលកបណ្ឌិតនេះ, ឥឡូវនេះ យើងអង្គុយក្នុងទីនុ៎ះ ដើម្បីនឹងសរសើរ
កិត្តិគុណនៃសេចក្ដីជ្រះថ្លារបស់ទុលកបណ្ឌិត ហើយខំចំរើនកម្មដ្ឋាន ប្រឹង-
ប្រែងព្យាយាម ដើម្បីតបឧបការគុណរបស់គាត់ទើបគួរ ។ លំដាប់នោះ
ភិក្ខុទាំងអស់ក៏ទទួលប្រតិបត្តិតាមពាក្យមហាថេរ ។ ព្រះថេរ គង់
ក្នុងទីនោះជាមួយនឹងភិក្ខុទាំងឡាយ ហើយចំរើនកម្មដ្ឋាន ប្រឹងប្រែង
ព្យាយាមក៏បានសម្រេចព្រះអរហត្តបដិសម្ភិទាញាណ ព្រមគ្នាទាំង ៣៣
រូប ។ ទើបព្រះនាគទីបកត្រេកដ៏មានអាយុ គិតថា "ស្ដេចនេះ ប្រកប
ដោយមិច្ឆាទិដ្ឋិ" ទើបលោកប្រឹក្សាគ្នាថា បើដូច្នោះគួរតែយើងទាំងឡាយ
ទៅសង្គ្រោះដល់ទុលកបណ្ឌិត ។ ភិក្ខុទាំងអស់នោះ ក៏មានសេចក្ដីប៉ុនប៉ង
តែបែបមួយ ក្រោកចាកអាសនៈ ឃុំចីវរ កាន់យកបាត្រហោះឡើងទៅ
កាន់អាកាសវេហាស៍ដូចជាកដហង្សឬដូចជាព្រះអាទិត្យ ដែលត្រេចទៅ
តាមផ្លូវអាកាសដូច្នោះ ។ ភិក្ខុខ្លះអង្គុយ ភិក្ខុខ្លះចង្រ្កម ភិក្ខុខ្លះសឹង ភិក្ខុ
ខ្លះស្ទាបអង្អែលមណ្ឌលព្រះចន្ទព្រះអាទិត្យ ភិក្ខុខ្លះឈរលើកំពូលភ្នំ ។
ភិក្ខុទាំងនោះបានសំដែងឥទ្ធិឫទ្ធិអស្ចារ្យជាអនេកប្រការ ។ គ្រានោះ ព្រះ
រាជាទតព្រះនេត្រឃើញហេតុជាទីអស្ចារ្យ ដែលមិនធ្លាប់មានយ៉ាងនេះ
ហើយ ក៏មានសេចក្ដីតក់ស្លុត ព្រឺព្រះលោមាព្រឺព្រះចម្មា មានព្រះកត្រ្តា
សំយុងចុះ ហើយត្រាស់ហៅពួកអាមាត្យថា ម្នាលអាមាត្យដ៏ចំរើនទាំង-
ឡាយ, ពួកចោរទុ៎ះហ្ន៎ហោះមកតាមអាកាស មានប្រាថ្នានឹងសម្លាប់យើង,
បើយ៉ាងហ្នឹង តើយើងគិតធ្វើដូចម្ដេច? គ្រានោះ អាមាត្យទាំងឡាយ

ក្រាបបង្គំទូលថា   បពិត្រព្រះសម្មតិទេព,   សូមព្រះអង្គត្រាស់ហៅទុលកបណ្ឌិតមកសួរ ៗ ព្រះរាជាក៏ត្រាស់ហៅទុលកបណ្ឌិតមក ៗ ទុលក-បណ្ឌិតមកដល់ក្រាបថ្វាយបង្គំព្រះរាជា ហើយអង្គុយក្នុងទីដ៏សមគួរ ៗ ព្រះរាជាត្រាស់សួរទុលកបណ្ឌិតថា ម្នាលអ្នក, ពួកចោរទាំង ៣៣ រូបដែលអ្នកឯងដោះលែង, ឥឡូវហោះមកតាមអាកាស បម្រុងនឹងសម្លាប់យើង, បើដូច្នោះបូរអ្នកឯងជួយដោះទុក្ខធុរៈយើងផង ៗ ព្រះពោធិសត្វបានស្តាប់ព្រះរាជឱង្ការៈហើយមានសេចក្តីកែកាយ ដូចជាព្រះចន្ទពេញវង់ ក្រាបបង្គំទូលទទួលការថា 'បពិត្រមហារាជ, សូមព្រះអង្គកុំភិតភ័យបារម្ភឡើយ" ហើយក្រាបបង្គំទូលថា "ទូលព្រះបង្គំជាខ្ញុំនិមន្តលោកទាំងនោះក្នុងថ្ងៃនេះ" លុះទុលកបណ្ឌិតលួងលោមព្រះរាជាឲ្យបានស្រួលព្រះទ័យហើយ ទើបឲ្យគេចាត់ចែងក្រាលអាសនៈបម្រុងទុក ៗ លំដាប់នោះព្រះរាជាកាន់យកគ្រឿងក្រអូបនឹងផ្កាកម្រងជាដើមឈរចាំក្នុងទីនោះ ៗ ទុលកបណ្ឌិតងើបមើលអាកាស ហើយផ្គងអញ្ជលីផ្គុំក្រពុំម្រាមដៃទាំង ១០ នមស្សការចំពោះព្រះអរហន្ត ពោលពាក្យយ៉ាងនេះថា :

ព្រះសង្ឃជាប្រទីបក្នុងត្រៃលោក   ព្រះសង្ឃជាព្រះអាទិត្យ
អាចកំចាត់បង់នូវងងឹតគឺអវិជ្ជា  ជនទាំងឡាយឯណាបានដល់
នូវព្រះសង្ឃជាទីពឹងទីរលឹក ភ័យមិនមានដល់ជនទាំងឡាយ
នោះសព្វ ៗ កាល   ៗ

ពុទ្ធសាវ័កទាំងនោះក៏ចុះចាកអាកាសមកគ្រប់អង្គ ៗ ទុលកបណ្ឌិតនិយាយថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន, ខ្ញុំព្រះករុណាឈ្មោះទុលកបណ្ឌិត សូមក្រាបថ្វាយបង្គំនិមន្តលោកម្ចាស់ ៗ លំដាប់នោះ ភិក្ខុទាំង ៣៣ រូបបានស្ដាប់ពាក្យទុលកបណ្ឌិតហើយ ក៏មកគង់លើអាសនៈដែលព្រះរាជាឲ្យក្រាលទុកបម្រុងក្នុងព្រះរាជនិវេសន៍ ៗ ទុលកបណ្ឌិតអង្គុយរំលឹកគុណភិក្ខុទាំងនោះ ៗ ព្រះរាជាថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយធ្វើសក្ការបូជា ៗ លំដាប់នោះ ព្រះនាគទីបកត្ថេរ សំដែងធម៌ចំពោះព្រះរាជាជាបទព្រះគាថាថា

សកិទេវ មហារាជ សព្ភិ ហោតិ សមាគមោ
សោ នំ សង្គមោ បាលេតិ នាសព្ភិ ពហុសង្គមោ ៗ
សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ៗ

បពិត្រមហារាជ, ការនៅរួមជាមួយនឹងពួកសប្បុរស សូម្បីតែម្ដងប៉ុណ្ណោះ ក៏ការនៅរួមនោះ អាចរក្សានូវអ្នកនោះមិនឲ្យមានអន្តរាយបាន, ឯការនៅរួមជាមួយនឹងអសប្បុរសទុកជាច្រើនដងយ៉ាងណា ក៏មិនអាចរក្សានូវអ្នកនោះបានឡើយ ៗ បុគ្គលគប្បីរាប់រកនូវពួកសប្បុរសតែម្យ៉ាង, គប្បីធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលដែលបានដឹងនូវព្រះ

សទ្ធម្មរបស់ពួកសប្បុរសហើយ ទើបបានជាអ្នកវិសេសថ្លៃថ្លា មិនមែនជាថោកទាបឡើយ ។ រាជរថដែលនាយជាងបានធ្វើវិចិត្រពេញដោយល្អ រមែងចាស់គ្រាំគ្រាទៅ, មួយវិញទៀត សូម្បីតែសរីរៈរាងកាយរបស់មនុស្សសត្វទាំងឡាយ ក៏រមែងចាស់គ្រាំគ្រាដែរ, មានតែធម៌របស់សប្បុរសទើបមិនចាស់គ្រាំគ្រាឡើយ; សប្បុរសទាំងឡាយ រមែងញុំាងពួកសប្បុរសផងគ្នា ឲ្យដឹងប្រាកដដូច្នេះ ។

មេឃនឹងដីជារបស់ឆ្ងាយដាច់ស្រយាលពីគ្នា, ត្រើយសមុទ្រខាងអាយនឹងត្រើយសមុទ្រខាងនាយ ក៏ឆ្ងាយដាច់ស្រយាលពីគ្នាដោយពិត, ចំណែកខាងធម៌របស់សប្បុរសនឹងអសប្បុរសប្រាកដជាឆ្ងាយជាងនោះទៅទៀត ។

គេហស្ថអ្នកបរិភោគនូវកាមគុណ ជាមនុស្សខ្ជិលច្រអូសមិនប្រពៃឡើយ, អ្នកបួសតែមិនសង្រួមឥន្ទ្រិយដោយប្រពៃក៏មិនល្អដែរ, ស្តេចធ្វើការឥតពិចារណា មិនល្អសោះឡើយ, អ្នកប្រាជ្ញមានសេចក្តីក្រោធ ក៏មិនល្អដូច្នោះដែរ ។

បុគ្គលឯណាវង្វេងជានិច្ច ហើយសាកសួរចំពោះបុគ្គលវង្វេងផងគ្នា បុគ្គលនោះឈ្មោះថារឹតតែវង្វេងដោយក្រៃលែង, បុគ្គលនោះមិនបានដល់នូវសួស្តីឡើយ រមែងដល់នូវសេចក្តី

គួបចិត្តជាប្រក្រតី ។ មិត្រមហាពជ, ការសេពគប់នឹងជនពាលបែបនោះ ក៏ដូច្នោះដែរ ។

បុគ្គលឯណាចង់ដើរក្នុងផ្លូវទេ ប៉ុន្តែត្រឡប់ជាទៅរកឯកំ្នវិញ បុគ្គលនោះ រមែងមិនបាននូវសួស្តីឡើយ តែងតែធ្លាក់ទៅក្នុងជ្រោះកំ្នជាប្រក្រតី ។

នរជនណាមួយ ខ្ចប់ប្រហុកដោយស្បូវក្រាំង, សម្បីតែស្បូវក្រាំងក៏តែងផ្សាយក្លិនស្អុយចេញមកដែរ យ៉ាងណាមិញ ការសេពគប់បុគ្គលពាល ក៏យ៉ាងនោះដែរ ។ នរជនឯណាមួយ ខ្ចប់ក្រស្នាខ្លឹមចន្ទន៍ ដោយស្លឹកឈើ, សូម្បីតែស្លឹកឈើ ក៏មានក្លិនក្រអូបផ្សាយចេញមកដែរ យ៉ាងណាមិញ, ក៏ការសេពគប់ជាមួយបណ្ឌិតក៏យ៉ាងនោះដែរ ។ បុគ្គលឯណាចូលទៅអាស្រ័យនឹងបុគ្គលពាល ស្និទ្ធស្នាលជាមិត្តសំឡាញ់ បុគ្គលនោះ តែងលិចចុះក្នុងសេចក្តីទុក្ខ ដូចជាពូជដែលគេបណ្ដុះហើយ ។ ជនឯណា បានធ្វើនូវអំពើអាក្រក់ ជននោះតែងបាននូវអំពើអាក្រក់វិញដែរ, ជនឯណា បានធ្វើអំពើល្អ ជននោះតែងបានសេចក្តីសុខដែរ ។ ជនទាំងអស់រមែងខ្លាចសេចក្តីទុក្ខ, ជនពាលរមែងខ្លាចសេចក្តីស្លាប់, ជនពាលរមែងជួបប្រសព្វនឹងឋាននរក, អ្នកប្រាជ្ញតែងជួបប្រសព្វនឹងព្រះនិព្វាន ។ ជនពាលមិនស្តាប់ពាក្យមាតាបិតា,

ជនជាអ្នកប្រាជ្ញតែងស្តាប់ពាក្យមាតាបិតា, ជនពាលមិនធ្វើតាមពាក្យគ្រូអាចារ្យ, ជនជាអ្នកប្រាជ្ញតែងធ្វើតាមពាក្យគ្រូអាចារ្យ ។ នរជនទាំងឡាយឯណា ចូលទៅសេពប្រកបការចំពោះបាបកម្ម, នរជនទាំងនោះ តែងទៅកាន់នរកធ្លាក់ចុះទៅក្នុងទីមិនសមគួរ ។ នរជនទាំងឡាយឯណា ជាអ្នកត្រេការនឹងបុណ្យ វៀរចាកបាបកម្ម, នរជននោះតែងទៅកាន់ឋានសួគ៌ តែងបាននូវសម្បត្តិសមតាមសេចក្តីប្រាថ្នា ។

លុះចប់ធម៌ទេសនាហើយ ព្រះរាជាអង្គនោះ ក៏មានសេចក្តីជ្រះថ្លាចំពោះព្រះរតនត្រ័យ ។ ព្រះអង្គ បានប្រគល់កាយថ្វាយខ្លួនចំពោះព្រះរតនត្រ័យ ហើយញុំាងពួកមហាជនឲ្យទូងស្គរប្រាប់អ្នកនគរទាំងអស់ ហើយទ្រង់ត្រាស់ព្រះរាជបញ្ជាថា នរណា ៗ ដែលនៅក្នុងខេត្តដែនរបស់យើង, អ្នកនោះកុំមានសេចក្តីប្រមាទចំពោះព្រះរតនត្រ័យឡើយ ។

ចាប់ដើមតាំងពីថ្ងៃនោះមក មនុស្សទាំងឡាយ អ្នកនៅក្នុងចិន-នគរក៏លះបង់មិច្ឆាទិដ្ឋិ បានតាំងក្នុងសម្មាទិដ្ឋិ ជាប់ដរាបមកដល់សព្វថ្ងៃនេះ ។ លំដាប់នោះ ព្រះរាជាទូលព្រះថេរៈយ៉ាងនេះថា "បពិត្រលោកម្ចាស់ដ៏ចំរើន ទោសគឺសេចក្តីក្តាំងក្តាត់ជាកាយកម្ម វចីកម្ម មនោកម្ម ដែលកន្លងទៅហើយ ដោយការនៅរួបរួមជាមួយនឹងបាបមិត្រ សូមលោកម្ចាស់អត់នូវទោសទាំងអស់នោះដល់ខ្ញុំព្រះករុណា" ហើយត្រាស់ព្រះរាជនិក្ខារដ្ឋបេះតទៅទៀតថា

ក្នុងកាឡបក្ខ (ចំណែកខាងរនោច) ព្រះចន្ទតែងតែសាបសូន្យទៅមួយថ្ងៃបន្តិចៗ យ៉ាងណាមិញ, បពិត្រលោកម្ចាស់ដ៏ចំរើន ការនៅប្រឡុកប្រឡំជាមួយនឹងពួកអសប្បុរសក៏មានឧបម័យដូចជាព្រះចន្ទក្នុងកាឡបក្ខយ៉ាងនោះដែរ, ខ្ញុំព្រះករុណា នៅរួបរួមជាមួយនឹងព្រាហ្មណ៍ដ៏លាមកថោកទាប ក៏មានឧបម័យដូចព្រះចន្ទខាងរនោចដូច្នោះ, ខ្ញុំព្រះករុណាទៅកាន់ទុគ្គតិដោយហេតុឯណា ហេតុនោះគឺបាបកម្មដែលខ្ញុំព្រះករុណាបានធ្វើហើយ ។

ព្រះចន្ទក្នុងសុក្កបក្ខ (ខាងខ្នើត) តែងចំរើនឡើងមួយថ្ងៃបន្តិចៗ យ៉ាងណាមិញ, បពិត្រលោកម្ចាស់ដ៏ចំរើន, ការនៅរួបរួមនឹងពួកសប្បុរស ក៏មានឧបម័យដូចព្រះចន្ទខាងខ្នើតយ៉ាងនោះដែរ, ការនៅរួបរួមជាមួយនឹងលោកម្ចាស់ ក៏ឧប-ម័យដូចជាព្រះចន្ទខាងខ្នើតដូច្នោះដែរ ។ បពិត្រលោកម្ចាស់ជាអ្នកប្រាជ្ញ, សូមលោកម្ចាស់ប្រាប់ខ្ញុំយ៉ាងនេះចុះ ខ្ញុំព្រះករុណាទៅកាន់សុគតិ ដោយហេតុឯណា ហេតុនោះក៏គឺកុសលដែលខ្ញុំបានធ្វើហើយហ្នឹងឯង ។

ព្រះរាជាទ្រង់ត្រាស់ដូច្នេះស្រេចហើយ ក៏បញ្ជូនព្រះថេរៈទាំងនោះឲ្យត្រឡប់ទៅវិញ ទ្រង់តាំងទុលកបណ្ឌិត ក្នុងដំណែងជាសេនាបតី ហើយទ្រង់បណ្តេញព្រាហ្មណ៍កំបាបអាក្រក់ បំបរបង់ចេញចាកនគរ ។

ពួកអ្នកនគរទាំងអស់ ក៏នាំគ្នាធ្វើបុណ្យមានឲ្យទានជាដើម ហើយទំនុកបំរុងព្រះសង្ឃដោយចតុប្បច្ច័យ ។

ព្រះរាជា មួយអន្លើដោយទុលកបណ្ឌិត ក៏ខំប្រឹងប្រែងធ្វើបុណ្យមានឲ្យទានជាដើម រៀងរាបដរាបដល់ទីបំផុតព្រះជន្មាយុ ទ្រង់សោយព្រះទិវង្គតទៅ បានទៅកើតក្នុងទេវលោក ។ ឯពួកអ្នកនគរទាំងអស់ខំប្រឹងប្រែងធ្វើបុណ្យមានឲ្យទានជាដើម រៀងរាបដរាបដល់ទីបំផុតអាយុ ក៏បានទៅកើតក្នុងទេវលោករៀងៗ គ្នា ។

សម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់នាំធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ទ្រង់ត្រាស់ព្រះពុទ្ធដីកាជាទីបំផុតថា ព្រាហ្មណ៍មិច្ឆាទិដ្ឋិ គឺជាទេវទត្ត. ព្រះរាជាដែលប្រទូស្តរ៉ាយព្រះសង្ឃនោះហើយបានស្លាប់ទៅក្នុងនរកទេតថាគត គឺជាអានន្ទ, ព្រះមាតាគឺជាព្រះនាងមហាមាយាជាពុទ្ធមាតា, ព្រះបិតា គឺជាព្រះបាទសុទ្ធោទន, ភរិយា គឺជានាងយសោធរពិម្ពា, កូន គឺជារាហុល, បរិសទ្យដ៏សេស ជាអ្នកធ្វើបុណ្យ គឺជាពុទ្ធបរិសទ្យ, ទុលកបណ្ឌិត គឺអង្គតថាគត ដែលជាទីពឹងនៃសត្វលោក ។ អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

- ចប់ ទុលកបណ្ឌិតជាតក ទី ១១ តែប៉ុណ្ណោះ -

## ផ្នែកអក្សរសាស្ត្រ

# រឿងសៅរ៍សោយ

(សិរិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៉ិង-ប៉ម
អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រាស្លឹករឹត

(តមក)

---

ក្សណៈនោះសាមណេរ ឮហើយងើយបែរ ឃើញឯសិរីសៅរ៍ មានចិត្តបីតិ មេត្រីព្រះចៅ ទើបស្ទុះទៅកើ ដោយទូវសាទរ ៗ នាំស្តេចស្លាប់ផ្ទះ ចេញពីទីនោះ ដោយស្មោះត្រេកអរ ហើយឲ្យស្តេចឈប់ ក្រោមម្លប់បវរ សាកសួរសាទរ ទៅវិញទៅមក ៗ ឯព្រះកជា រីងតែវេទនា ឈឺធុរធុរតក ដែលត្រូវដំណំ ជាំក្រំរបក ឈាមជ័រហូរមក ពេញវង់អង្គា ៗ ណាមួយខ្សោយអង្គ ពុំអាចផ្ចិតផ្ចង់ ទ្រទ្រង់ទុក្ខា កំទេតព្រះអង្គ ដួលតួងនៅនា ដិតខឿនសីមា ល្ហិតៗ និត្យនៅ ៗ

សាមណេរតូចនោះ យល់ហេតុភេទខ្លោះ រន្ធត់រត់ទៅ ប្រាប់ភិក្ខុគ្រប់អង្គ ដែលគង់វង់នៅ ថា“សូមទានទៅ ដ្បិតមានមនុស្សមក ៗ

ខ្លួនមនុស្សនោះហោង មានស្នាមដំបៅ រាយបងពងពក ដើរម្នាក់ឯង គួរ ឥឡូវមកដេក មិនដឹងជាមក ពីស្រុកឯណា ” ។

ភិក្ខុផងទាំងនោះ ព្រះនេនពោលគ្នា ថាមនុស្សពិក នាំគ្នាមកដល់ បានយល់ពជា សង្វេគគប់គ្នា វេទនាឥតបើ ។ មានចិត្តមេត្តា អា-សូរករុណា ដល់មហាចក្រី លុះឃើញក្សត្រក្សាន្ត ទ្រង់មានស្មារតី ទើបចូលជិតខ្ចី ស្តីថា៖ ”ញោមអើយ ។ មកពីស្រុកណា មកមាន កាយា ទុក្ខឥតស្បើយ ?” ទើបក្សត្រឧត្តម ប្រណម្យទើបឆ្លើយ សំពះថ្វាសំឆ្លើយ ទូលតបទៅថា ។ “ឱ! ព្រះគុណម្ចាស់ ព្រះគុណ ផូនណាស់ ខ្ញុំព្រះករុណា ជាតិជាមហាក្សត្រ ប្រាសព្រាត់ឃ្លាតឃ្លា ពីនគរ វេទនាស្មើរក្ស័យ ។ ខ្ញុំនេះព្រះគុណ ពីដើមធ្វើមបុណ្យ ជុំច្រើន ណាស់នៃ ផាស្ដេចសោយពជ្យ អំណាចពេកក្រៃ តែកម្មចង្រៃ តាម ទាន់នេះម្ដង ។ ហាក់ដូចផ្កាពិត រង្វើងខ្ទេចចិត្ត ចេញហាកមកហោង ទឹងសេះអាជានេយ្យ ប្រពៃកន្ទង ព្រះវាន់ ១ ផង ទឹងមកុដកែវថ្ងៃ ។ ជាប់មកទឹងខ្លួន តែកម្មចាំផ្ទួន ចំនួនក្រាស់ក្រៃ ទ្រព្យខ្ញុំប៉ុហ្នឹង សុទ្ធ សឹងទ្រព្យថ្លៃ មានអាចក្រៃ មកវ៉ៃ(១) យកទៅ ។ រាងកាយរាបង បែក ក្បាលបែកខ្នង ឈាមផងព្រាលផ្លៅ ខ្ញុំមកដល់នេះ មិនអាចដើរទៅ ទើបសូមស្នាក់នៅ តទៅលុះជា” ។

---

• ពាក្យត្រឹមត្រូវ “វាយ” ។

អស់ទាំងភិក្ខុផង បានជីវិតទំនង ជាអង្គពជា មានចិត្តសាស្បូរ
អំបូរពុទ្ធា ទើបនាំគ្នា រកថ្នាំដំបៅ ៗ ខ្លះក៏ចាត់ចែង ឲ្យនេននោះឯង
រកថ្នាំទឹកក្តៅ យកមកស្រោចលាង អស់ទាំងដំបៅ ដាក់ថ្នាំក្នុងក្រៅ
តំលាបផឹកផង ៗ ខ្លះក៏បោសស្អំ ដំណាំថ្នាំក្រំ ពីមុខពីខ្នង ស្ដេចបាន
ស្រាន្តឈឺ ជម្ងឺនោះហោង អស់ទាំងភិក្ខុផង ថ្វាយភោជន៍ភោត្តា ៗ
នាំគ្នាកែវៈ ខ្លះបានបបរ ខ្លះក៏បាយណា ខ្លះបានទៀតរ៉ស់ ខ្លះបាន
ទៀតត្រា ថ្វាយស្ដេចភោត្តា នាគ្រានោះហោង ៗ

សម្តេចសិរសៅរ៍ ប្រកបបួបនៅ ទីងគុណសង្ឃផង មើលថែ
ក្សត្រក្សាន្ត សព្វហានគ្មានហ្មង ពីរបីថ្ងៃហោង សះជាអាពាធ ៗ
បានសុខសប្បាយ អស់អង្គកាយ ក្សត្រថ្ងៃភូវនាថ ប្រកបបួបត្រង់
គុណសង្ឃជាអាទ៍ ផ្ចិតផ្ចង់សង្វាត ដោះទុក្ខសព្វសត្វ ៗ

សំនួរសួរថា "សង្ឃត្រប់អាត្មា នាំគ្នាប្រតិបត្តិ ថែទាំភេគា
នៃមហាក្រសត្រ(១) ឲ្យបាត់ឈឺចាត់ តើព្រោះហេតុអ្វី?" ៗ

ចំឡើយឆ្លើយថា "ព្រោះមហាក្សត្រា កាលសាងបារមី ស្ដេច
ត្រាច់វិលវង់ ទៅក្នុងភពបី ពេលមួយចក្រី បានកើតជាតិជា ៗ
បុរស ១ នាក់ ឈ្មោះកុលកៈ ជាអ្នកប្រាជ្ញថ្លា លោកបានឲ្យទាន ជីវិត
អាត្មា ដល់សង្ឃត្រប់គ្នា នោះជាហេតុផល ៗ ដូច្នោះបានជា ភិក្ខុសព្វ

---

១ ពាក្យត្រឹមត្រូវ "ក្សត្រ" ឬ "ក្សត្រិយ៍" ។

គ្រប់គ្នា លីលាមកយល់ ព្រះបាទបមចក្រ ទុក្ខធ្លាក់មកដល់ នាំគ្នារចល់ ថែទាំគ្រប់អង្គ" ។

ស្ដេចនៅទីនវត្ត ហើយក៏ប្រយ័ត្ន ប្រតិបត្តិសត្យសង្ឃ បន្តិច ស្ដេចឃើក ត្រេកនឹកចង់ បួសធ្វើជាសង្ឃ ក្នុងពុទ្ធសាសនា ។ វរពុទ្ធរ ចូលជិតពិតទូល ដល់សង្ឃផងថា "បពិត្រអម្ចាស់ ខ្ញុំព្រះជ្រះថ្លា ចិន្តាប្រាថ្នា បួសជាសង្ឃនៃក្រ ។ សូមមានមេត្តា បំបួសផងក៏ យកជា និស្ស័យ" ពេលនោះអស់សង្ឃ គ្រប់អង្គអរក្រៃ ពោលថា "ក្សត្រថៃ ល្អក្រៃណាស់ហោង ។ គ្រឿងបរិក្ខារ មានគ្រប់ប្រការ ឃើញថា គ្មានហ្មង ខ្វះតែចីវរ ដែលក្រកម្មង់ ពុំដឹងទាក់ទង រកបានពីណា" ។

ព្រះមហាក្សត្រក្សាន្ត ទូលថា "សូមមាន ខ្ញុំមានកូសា សម្រាប់ ដណ្ដប់ នេះជាប់មកណា សូមមានមេត្តា ចាត់ការឲ្យមាន" ។

ភិក្ខុផងគ្នាន់គ្នេរ នាំគ្នាកាត់ដេរ ស្រេចគ្រប់សព្វប្រាន ទើបនាំមក ចាត់ ថ្វាយថ្វាត់ក្សត្រក្សាន្ត ស្រេចស្រួលទូលថ្កាន "សូមមាននរនាថ ។ សូមព្រះភូធរ ទ្រង់យកចីពរ ទៅគក់សំអាត ហើយតាំងក្រាក់ខ្នុរ ដាក់ស្បោរទុហាត ផ្ចិតផ្ចង់ស្អាត ដែលក់ទៅហោង" ។

ក្សត្រថៃពទូក ទទួលយកមក រៀបចំផ្គុំផ្គង តែទ្រង់ចិន្តា ថា "ការ នេះហោង បើធ្វើតែម្តង ក្នុងវត្តនេះណា ។ ផ្សែងផងគង់បក់ ឲ្យសង្ឃ ផងល្មក់ រីកទុក្ខា បេះគួរអញទៅ សេក្ការក្រៅសីមា" គិតហើយក្សត្រា

លីលាចរចុះ ៗ ដល់ស្រេចស្រេចទ្រង់ ពុំគង់បង្អង់ ទើបទ្រង់ពុះឆុស
ផុតស្មោរក្រាក់ខ្ទរ លុះដល់វាពុះ រំងាស់ទៅលុះ លួមបានដែលក់ ៗ
ដង់ទឹកនោះមក ដាក់ស្មុករបយក បីរវដែលគក់ ជ្រះស្អាតម៉ត់ចត់
សង្កត់ដែលក់ ល្មោបឈ្មោញ៉ាញក់ ពាក់ហាលលើខ្សែ ៗ យកទឹកសល់
នៅ រមាស់ទៀតទៅ ផុតក្រើងបន្ទៃ សង្ហាតដែលក់ គ្មានតក់គ្មានល្ហៃ
ហាលហើយទៅប្រែ ដោយក្តីប្រយ័ត្ន ៗ ថ្ងៃនោះដៀងដាក់ មានជន ៤
នាក់ ស្ទះស្នែងខ្វែងខ្វាត់ ដើរតាមរកគោ ដ្បិតគោវាបាត់ ដើរត្រដក
រកស្កាត់ ពុំឃើញឡើយណា ៗ ទៅ ៗ តាមផ្លូវ ក្បែរណានោះឯងក្បូរ
ងាកទៅឃើញថា មានផ្សែងខ្មៅខ្មួល បបួលគ្នីគ្នា ចូលទៅម្នីម្នា ដល់
មហាក្បែរថ្ងៃ ៗ បុរស ៤ នាក់ មើលទល់យល់ជាក់ បីររនោះនៃ
ឃើញជាស្បែកគោ ពិតឥតសង្ស័យ វត្តពន្ធប្រែរ ដារពោះវៀនពិត ៗ
ឯចំណាំងក្រាក់ ប្រែខ្វៃបែរដាក់ ទៅជាចំណិត នៃដុំសាច់គោ ទឹង
គ្រឿងក្នុងពិត ទឹកក្រាក់ល័ក្ខជិត ជាឈាមគោណា ៗ របស់ប្រាំ
ក្វាយប្លុកចំណាំ ព្រោះកម្មក្បែត្រា បុរស ៤ នាក់ យល់ជាក់នេត្រា
សំគាល់ស្តេចថា ជាក់ជាចោរហោង ៗ បង្កើតចិត្តក្រោធ ខឹងឃោរ-
ប្រចឡោត លោចាប់ដំបង វាយព្រះទ្រង់យស បែកអស់ទាំងខ្នង
ខ្ទះធាក់ទាត់ផង លុះដួលដល់ដី ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ២០

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្ដានស្នេហាជាតិ ។

ទៀតពីលុះឃើញកងទ័ពលើកមកពីចម្ងាយ ក្រឡេកឃើញទង់ជ័យសម្រាប់ទ័ពបូព៌ា ក៏សំគាល់ថាបូព៌ាលើកមកខ្លួនឯង ៗ, បំរើសេះល្បាតមកប្រាប់ទៀតពីថា កងទ័ពអ្នកសៀវប្រឹក្សាមិនចុះរុះគ្នា នៅការងមិនបានចេញច្បាំងនឹងបូព៌ាទេ ១ ទៀតកងទ័ពបូព៌ានោះ នឹងបានឃើញទង់ជ័យសម្រាប់ទ័ពបូព៌ាក៏ឥតអគ្គីមាន កាលខ្ញុំបាទត្រឡប់មក ប្រទះនឹងកងទ័ពលើកមកជិតស្រុកនេះហើយ ឃើញទង់ជ័យសម្រាប់ទ័ពបូព៌ាដោតពីមុខ តែខ្លួនបូព៌ានឹងនៅក្នុងកងទ័ពនេះឬក៏ទ័ពខាងណាៈមិនច្បាស់ប្រាកដ ៗ

ទៀតពីបានស្ដាប់ដូច្នោះ ក៏ប្រឹក្សានឹងគាន់តេងតាមពាក្យបំរើសេះ ហើយថា យើងមានសេចក្ដីសង្ស័យមិនដឹងជាបូព៌ានៅខាងកងទ័ពណា ៗ

គាត់តែងឆ្លើយថា កលឧបាយប្អូននោះមានច្រើនប្រការណាស់ ក្រែមមនុស្សណានឹងដឹងដល់ ដែលកងទ័ពនៅការពារបុរីនឹងច្បាំងអ្នកសៀមនោះ គ្មានទន់ជ័យស្រាប់ទ័ពប្អូនសោះ ខ្ញុំបាទយល់ថា ប្អូនមុខជានៅក្នុងកងទ័ពនោះជាប្រាកដ ឯកងទ័ពដែលលើកមកខាងស្រុកយើងនេះទាហានកំតិច តែទន់ជ័យស្រាប់ប្អូនមកផង ដែលប្អូនគិតធ្វើការគ្រានេះប្រាជ្ញានឹងឲ្យលោកបារម្ភក្រែងថា ខ្លួនប្អូនមកក្នុងកងទ័ពនេះ ។

ទៀតពីបានស្តាប់ដូច្នោះក៏ងាកទៅសួរគួនអ៊ីតៀវហ៊ុយថា ប្អូនទាំង ២ នាក់ តើនរណានឹងយកអាសាចេញទៅធ្វើការ ឲ្យដឹងច្បាស់ហេតុផលជាប្អូនមកឬមិនមក? ។ តៀវហ៊ុយឆ្លើយទទួលថា ខ្ញុំបាទសុំយកអាសាចេញទៅធ្វើការឲ្យដឹងហេតុ. បើជួបនឹងប្អូនហើយខ្ញុំបាទនឹងចាប់ខ្លួនប្អូនមកឲ្យបាន ។ ទៀតពីនិយាយតបទៅតៀវហ៊ុយវិញថា ប្អូនឯងនៅក្មេងសេចក្តីខ្លីគំនិតណាស់ តាំងចិត្តថ្លើមក៏រួសរាហ៊ាស នឹងឲ្យទៅមិនបានទេ ។ គួនអ៊ីថាខ្ញុំបាទសុំយកអាសាចេញទៅធ្វើការ ។ ទៀតពីថា បើគួនអ៊ីចេញទៅយើងល្មមទុកចិត្តបាន ។ គួនអ៊ីក៏លាទៀតពីលើកទាហានសេះ ៣ ពាន់ចេញទៅ ពេលនោះទេសកាលជារដូវរងាទឹកសន្សើមចុះខ្លាំងណាស់ ទាហានទាំងពួងក៏រងាត្រជាក់ពន់ពេក គួនអ៊ីខំស្វាហ៍នាំទាហានចូលទៅដល់មុខបន្ទាយអងតុង ហើយគួនអ៊ីបរសេះចេញទៅឈរមុខទាហានស្រែកថា នរណាជាមេទ័ព ចូរប្រញាប់ចេញមកយើងនឹងសាកសួរ ។

អង្គុងបានឮគួនអ៊ូស្រែកសួរដូច្នោះ ក៏ជិះសេះចេញមកឈរនៅមុខបន្ទាយហើយស្រែកប្រាប់ថា មហាឧបរាជលើកមកដល់ទីនេះហើយ ហេតុម្ដេចខ្លួនទើបមិនចូលមកគំនាប់ ។ គួនអ៊ូតបថា បើមហាឧបរាជមកមែនឲ្យអញ្ចើញចេញមក យើងនឹងថ្លែងសេចក្ដីជំរាបលោក ។ អង្គុងតបថា ខ្លួនជាអ្នកតូចទាបគួរប្អូននឹងឲ្យមហាឧបរាជចេញមកជួប ។ គួនអ៊ូខឹងណាស់ ក៏បរសេះកំដារចូលទៅ ។ អង្គុងក៏បរសេះកំលំពែងចេញមកតច្បាំងនឹងគួនអ៊ូបាន ៥ ក្បួន ។ គួនអ៊ូធ្វើជាញាក់សេះថយរត់ទៅក្រោយ ។ អង្គុងមិនដឹងកលក៏ដេញបណ្ដោយតាមដល់ជើងភ្នំ គួនអ៊ូបកមកតទល់ដល់ជិតគ្នា ទើបលើកដាវឡើងកាប់ឲ្យអង្គុងគេចចុះ ហើយគួនអ៊ូក៏ស្ទុះទៅរួបចាប់យកខ្លួនអង្គុងបាន ដាក់លើសេះពីក្រោយនាំចូលទៅឲ្យឡេវពី ហើយពណ៌នាឲ្យឡេវពីស្ដាប់គ្រប់ប្រការ ។ ឡេវពីក៏មានចិត្តសោមនស្សប្រីតា តែមិនបានស្គាល់កិរិយាអង្គុងច្បាស់ក៏សាកសួរថា អ្នកឯងជានាហ្មឺនបូច្ចូតំណែងអ្វី? ហេតុម្ដេចមកធ្វើកលឧបាយក្លែងថា បូច្ចូមកនៅក្នុងកងទ័ពនេះ? ។ អង្គុងឆ្លើយថា ខ្ញុំបាទឈ្មោះអង្គុងជាទីសេនាពោរបស់បូច្ចូ ឯខ្លួនបូច្ចូមិនបានមកក្នុងកងទ័ពនេះទេ ឲ្យខ្ញុំបាទនឹងឡេវ-តាយលើកទ័ពមក គំនិតខ្ញុំបាទនឹងបានគិតធ្វើកលសឹកខ្លួនឯងក៏ទេ ដែលយកទង់ជ័យសម្រាប់ទ័ពបូច្ចូលើកមកក្នុងកងទ័ពនេះ ព្រោះបូច្ចូបង្គាប់ប្រើ, ខ្ញុំបាទខ្លាចអាជ្ញាក៏ធ្វើតាមបង្គាប់បូច្ចូ ។ ឡេវពីបានស្ដាប់ ក៏យកគ្រឿង

សម្ញែកបំពាក់ ១ ប្រដាប់មកឲ្យអង់តុង ហើយរៀបតុលៀងគោជនាហារ ឲ្យអង់តុងបរិភោគ រួចឲ្យទាហានយកខ្លួនអង់តុងទៅឃុំទុក បើចាប់ឡៅតាយបានវេលាណាទឹងបានគិតការតទៅទៀត ។

គួនអ៊ូនិយាយនឹងឡៅតីថា ខ្ញុំបាទប្រមាណចិត្តលោកឃើញថា លោកនៅប្រម្ភាចចិត្តប៉ួច បានជាមិនសម្លាប់អង់តុងចេញ បើដឹងដូច្នេះ ខ្ញុំបាទមិនចាប់ទាំងរស់មកជូនលោកទេ ។ ឡៅតីតបថា ដែលយើងមិនប្រើតៀវហ៊ុយឲ្យចេញទៅនោះ ព្រោះគិតឃើញថាចិត្តតៀវហ៊ុយរួសរហ័សណាស់ បើចាប់មេទ័ពបានមុខជានឹងសម្លាប់មិនខាន ដែលយើងបានខ្លួនអង់តុងមកទុកដូច្នេះ ទោះបួចនឹងជាប្រការម្ដេចក៏មានផ្លូវនឹងដោះស្រាយកែខៃទៅបានដោយងាយ ។

តៀវហ៊ុយក៏ជំរាបឡៅតីថា គួនអ៊ូទៅចាប់ខ្លួនអង់តុងបានមកហើយ ខ្ញុំបាទនឹងសុំយកអាសាចេញទៅចាប់ខ្លួនឡៅតាយមកជូនលោកទៀត ។ ឡៅតីតបថា ឯឡៅតាយនោះជាចៅហ្វាយស្រុកគុយជីវ កាល ចៅហ្វាយខៃត្រទាំង ១៨ មណ្ឌល លើកទៅកំចាត់តាំងតុតីគ្រាមុននោះ ឡៅតាយក៏លើកពលទៅធ្វើការជាមួយផង គ្រានោះបួចឃើញឡៅតាយមានដំរេះប្រាជ្ញា បានជាប្រើឲ្យធ្វើមេទ័ពលើកមក ដែលប្អូនឯងនឹងលើកទាហានចេញទៅចាប់ខ្លួនឡៅតាយនោះ បងយល់ឃើញថាមិនមែនបានតាមបំណងគិតទេ ។ តៀវហ៊ុយឆ្លើយតបថា ទឹងរាប់ទុកជា

ពូកែដូចម្តេចថ្វីដៃឡាតាយប៉ុណ្ណោះ ខ្ញុំបាទនឹងចាប់យកមកឲ្យបាន ។ ឡៅពីថា បងក្រែងប្អូនឯងចេញទៅច្បាំងនឹងធ្វើឲ្យអន្តរាយដល់ជីវិត ឡាតាយតែម្តង មិនបានខ្លួនរាំងរស់មកដូចជាគួនអ៊ូ ។ តៀវហ៊ុយថា ខនេះលោកកុំវិតក្កះឡើយ បើខ្ញុំបាទសម្លាប់ឡាតាយក្តី ឬចាប់ខ្លួនមិនបានមកទាំងរស់ក្តី ឲ្យលោកកាត់ក្បាលខ្ញុំបាទចេញ ។ ឡៅពីបានឮដូច្នោះក៏ពេញចិត្តណាស់ ទើបចាត់ទាហានសេះ ៣ ពាន់ឲ្យតៀវហ៊ុយ ។ ក៏លាឡៅពីលើកចេញទៅ ។

ឯឡាតាយកាលដឹងថា គួនអ៊ូចាប់ខ្លួនអង្គុងទៅបាន រួចឃើញតៀវហ៊ុយលើកទ័ពមកទៀត ឡាតាយក៏ទឹកញើតដៃតៀវហ៊ុយមិនបានចេញច្បាំង ប្រឹងតែរក្សាបន្ទាយរាយកងទ័ព យាមល្បាតពីក្នុងបន្ទាយ ។ ឯតៀវហ៊ុយនោះលុះមិនឃើញឡាតាយចេញមកច្បាំងសោះ ក៏លើកទាហានចូលទៅដល់មុខបន្ទាយឡាតាយ ហើយឲ្យទាហានស្រែកជេរជាពាក្យអាស្រូវាសផ្សេងៗ ។ ឡាតាយក៏សម្ងំស្ងៀមមិនបានលើកទ័ពចេញច្បាំង ដែលការដូច្នេះគ្រប់ ៥ ថ្ងៃ ។ តៀវហ៊ុយក៏គិតកលឧបាយបង្គាប់ទាហានទាំងពួងថា កណ្តាលយប់ស្អាត់ក្នុងថ្ងៃនេះ ពេលយាម ៣ ប្វាយ យើងនឹងលើកចូលទៅប្លន់យកបន្ទាយឡាតាយឲ្យបាន ឲ្យទាហានទាំងអស់ត្រៀមខ្លួនឲ្យស្រេច ។ តៀវហ៊ុយផឹកស្រាហើយធ្វើកិរិយាបែបស្រវឹងមិនដឹងខ្លួន ក៏រករឿងយកទោសទាហានម្នាក់ ឲ្យវាយ

ប្រហែល ៣០ រំពាត់ ហើយនិយាយនឹងទាហានដែលមានទោសនេះថា ពេលយាម ៣ ផ្លាយក្នុងយប់នេះ យើងនឹងកាត់ក្បាលឯងសែនទង់ជ័យ ហើយលើកពលចូលទៅវាយបន្ទាយឡៀតាយ ។ គៀវហ៊ុយបង្គាប់ឲ្យចងទាហាននោះទុក ។ លុះពេលយាម ១ ផ្លាយ គៀវហ៊ុយក៏លបប្រើមនុស្សឲ្យចូលទៅស្រាយចំណងទាហានមានទោសនោះចេញ ទាហាននោះក៏លបរត់ទៅដោយមានចិត្តខឹងក្តៅនឹងខ្លាចសេចក្តីស្លាប់ ក៏គេចចូលទៅក្នុងបន្ទាយឡៀតាយ ហើយនាំយករឿងដែលគៀវហ៊ុយគិតនោះប្រាប់ឡៀតាយគ្រប់ប្រការ ។ ឡៀតាយបានស្តាប់ហើយឃើញរបួសស្នាកស្នាមទាហាននោះជាបន្ទាល់ ក៏គ្មានពិកាល់សង្ស័យសំគាល់ថាពិត ទើបកេណ្ឌទាហានឲ្យចេញទៅពួនបង្កប់ក្រៅបន្ទាយជា ២ កង ក្នុងបន្ទាយនោះគ្មានមនុស្សនៅសោះ ។

គៀវហ៊ុយដឹងថាទាហានដែលមានទោសត្រូវវាយនោះរត់ទៅហើយ ក៏គិតថា ហេតុល្អអាក្រក់ទាហាននេះវាគង់រត់ទៅប្រាប់ឲ្យឡៀតាយដឹង មុខជាឡៀតាយនឹងចោលបន្ទាយ ឲ្យទាហានចេញពួនបង្កប់មិនខាន អញនឹងរិះគិតការត្រួតកលចាប់ខ្លួនឡៀតាយឲ្យបាន ។ លុះដល់ពេលយាម ៣ ផ្លាយ គៀវហ៊ុយក៏លើកទាហានញែកគ្នាទៅពួនបង្កប់ជា ២ កង ហើយបង្គាប់ថា បើឃើញពន្លឺភ្លើងឆេះបន្ទាយឡៀតាយ ត្រូវឲ្យលើកគ្នាវាយប្រសព្វខ្ទប់ទាំងសងខាង ខ្លួនគៀវហ៊ុយជាកងកណ្តាលប្រទាំ

ជូន ហើយបង្គាប់ទាហាន ៣០ នាក់ជាកងមុខឲ្យចូលទៅប្លន់អុជភ្លើងឲ្យឆេះបន្ទាយឲ្យបាន ៗ ទាហាន ៣០ នាក់ក៏លើកចូលទៅប្លន់បន្ទាយហើយដុតភ្លើងឆេះឡើង ៗ

ឯទាហានឡៅតាយដែលពួនបង្កប់ទាំង ២ កង លុះឃើញដូច្នោះក៏លើកកាយខ្ទប់ទាំងសងខាង ៗ ទាហានតៀវហ៊ុយដែលបង្កប់នៅពីខាងក្រៅ នឹងខ្លួនតៀវហ៊ុយ លុះឃើញពន្លឺភ្លើងឆេះឡើងក្នុងបន្ទាយនៃឡៅតាយ ក៏លើកសម្រុកចូលទៅកាយខ្ទប់ជា ៣ ផ្លូវ ៗ ចំណែកទាហានឡៅតាយដែលបានឃើញទាហានតៀវហ៊ុយកាយខ្ទប់ពីក្រោយ ហើយចាក់កាប់សម្លាប់ខ្លះរបួសពីការខ្លះ ទាហានទាំងនោះក៏បែកខ្ចាត់ខ្ចាយទៅខ្លះ ៗ តៀវហ៊ុយក៏បរពលចូលប្រយុទ្ធនឹងឡៅតាយបានមួយស្របក់ តៀវហ៊ុយក៏ចាប់ខ្លួនឡៅតាយបានហើយឲ្យទាហានចងទុក ៗ បណ្ដាទាហានដែលបែកខ្ញែកទៅនោះ ក៏ត្រឡប់ចូលមកបំណុះចុះចូលតៀវហ៊ុយជាច្រើន តៀវហ៊ុយក៏ឲ្យទាហានស្រុតទៅជំរាបឡៅពី ៗ បានស្ដាប់ក៏មានសេចក្ដីត្រេកអរ ហើយនិយាយនឹងគួនអ៊ូថា តៀវហ៊ុយជាមនុស្សចិត្តស្រាលរហ័សកាចសាហាវណាស់ គ្រានេះគិតកលឧបាយចាប់ខ្លួនឡៅតាយបាន ដែលតៀវហ៊ុយមានសតិបញ្ញាគិតឃើញបានការដូច្នេះ ដោយបុណ្យសំណាងរបស់យើង១ មានសេចក្ដីសប្បាយចិត្តណាស់ ៗ

លុះវេលាព្រឹកឡើង ឡាវពីក៏នាំគួនអ៊ូចេញទៅទទួលដល់ក្រៅកំពែងស្រុក ត្រៀវហ៊ុយឃើញឡាវពី, គួនអ៊ូទៅដល់ក៏ចូលមកគំនាប់ ហើយនិយាយថា បងតិះដៀលថា ខ្ញុំបាទជាមនុស្សចិត្តស្រាលរហ័ស ឥឡូវខ្ញុំបាទបេះរិះគិតឧបាយកលចាប់ខ្លួនឡាវតាយបាន បងបានឃើញដំរេះប្រាជ្ញាខ្ញុំបាទហើយឬ? ។ ឡាវពីតបថា បើបងមិនសង្កត់សង្កិនប្អូនឯងយ៉ាងនេះទេប្អូនឯងក៏កើនចិត្ត ណាឡើយនឹងរិះគិតចាប់ខ្លួនឡាវតាយបាន ។ ត្រៀវហ៊ុយក៏អស់សំណើច ទើបឡាវពីចុះពីលើសេះបូលទៅស្រាយចំណងឡាវតាយចេញ ហើយនិយាយថា "ដែលប្អូនយើងបានទៅធ្វើអ្នកដល់ទីនេះ អ្នកប្ដូរអភ័យទោសចុះកុំបីប្រកាន់ឡើយ" និយាយហើយឡាវពីក៏នាំឡាវតាយចូលទៅក្នុងស្រុក ហើយឲ្យរៀបតុលៀងភោជនាហារ ប្រើបំរើឲ្យទៅនាំខ្លួនអងតុងពីក្នុងឃុំនាំមកបរិភោគជាមួយនឹងឡាវតាយ ។

(មានត)

## ភ្ញៀវជាពន្លឺនៃម្ចាស់ផ្ទះ

ជនជាសំឡាញ់មកកាន់ផ្ទះនៃជនណា ដើម្បីកិច្ចការណាមួយ ជននោះឈ្មោះថា ជាអ្នកមានបុណ្យ ជាអ្នកមានកល្យាណធម៌ ជាអ្នកគួរគេសរសើរ នៅនាលោកនេះ ។

បញ្ញត្រ្ត:

ដំណើរតាមខ្យល់ក្នុងគគនដ្ឋារៈ

# លោកផេង-ជ្រើវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

លោកម៉ារីយ៉ារំពឹងថា "បើវាទៅកាលខ្សាច់ពេលនេះ គឺប្រយោជន៍នឹងចាប់យកស្រីក្រមុំ ម៉្លោះហើយមុខជាបង្ហាញខ្លួនអញទៅរកទោស ហើយសក្ដិយសរបស់អញនឹងរបេះចេញជាប្រាកដ" លុះគិតដូច្នោះហើយ ទើបគិតតទៅទៀតថា "ណ្ហើយកុំចុះ, អំពាមួយមកដល់មាត់លុងហើយ" ។ ក៏ឆ្លើយថា:

– "អញត្រឡប់ទៅកាលខ្សាច់មិនបានទេ . . . ។ រហួសហើយៗ ណាជិតយប់ផង ។ អញត្រូវទៅឲ្យដល់ក្រុងកាសិ-កាពប៊ូលីឲ្យស្មើពេលគ្នានឹងលោកនាយរបស់អញ" ។

នាងឡូឡាស្រដីទៀតថា : "ខ្ញុំម្ចាស់ សូមអង្វរលោកម្ដង !" ។ នាយទាហានរញឹមៗ ហើយយកដើមសុទ្ធតែពេមស្រមូវមកកៀសដៃនាងដែលកំពុងលើកប្រណម្យអង្វរ ។

ខណៈនោះ លោកតាម៉ាព្រកអែលតាឌី ដែលចេះតែសំគាល់ចាំស្ដាប់ការណ៍អ្វីមិនមានខ្វះត្រង់ណា ក៏ដើរចូលមករកលោកព្រិន្ទបាល ជូនគំនាប់ដោយសេចក្ដីគោរព ហើយនិយាយថា :

– " នាងនេះជានារីកូនកុលសម្ពន្ធរបស់ខ្ញុំ បើប្រសិនជាលោកបើកច្បាប់ឲ្យខ្ញុំប្រើមនុស្សខ្ញុំម្នាក់ឲ្យទៅរកបងរបស់វាក៏បាន" ។

លោកម៉ារយោបើកភ្នែកបំពោកតាមត្រក ហើយតាំងសំឡក់ចង់ស៊ីសាច់ដោយបញ្ចេញសំដីថា :

– " អាឯងមានការអីមកលាយឡំជាមួយនឹងគេដែរ? អាឆ្កែ ! អាឯងដឹងឬទេត្រង់នេះ ដាច់ស្រេចលើអញ" ហើយគាត់ងាកទៅបង្គាប់ទាហានម្នាក់ថា : " ចាប់ក្មេងនេះដាក់លើសេះឡើង ។ នាងនេះត្រូវចិត្តអញ ៗ យកវារក្សាទុកសម្រាប់ខ្លួនអញ !" ។

ទាហាននោះធ្វើតាមភ្លាម ៗ នាងឡូឡាប្រឹងផង ស្រែកផង តែឥតអំពើ ។ គេលើកនាងឡើងដូចស្ទូកកណ្តាបដាក់លើខ្នងសេះ ។ នាងមើលឃើញបងស្រីរបស់ខ្លួន គេបោះបង់ចោលកណ្តាលវាលខ្សាច់ស្ងាត់តែម្នាក់ឯង ។ ខណៈនោះ ការអស់កំឡាំងនឹងសេចក្តីទុក្ខព្រួយញាំញីនាងពន់ពេក ម្ល៉ោះហើយនាងក៏បណ្តោយខ្លួនឲ្យប្រព្រឹត្តទៅតាមយថាកម្មកងកណ្តាប់ដៃទាហាន ហើយនាងសន្លប់បាត់មាត់ឈឹង ។

លោកព្រិន្ទបាលៈគាម៉ារយោ ញញឹមពេញចិត្ត គាត់ចាប់លើកកំប៉ុងស្រាផឹក ហើយធ្វើសញ្ញាដល់ពួកទាហានឲ្យធ្វើដំណើរតទៅទៀត ។

*
* *

ព្រះអាទិត្យទើបនឹងលិចបាត់ពន្លឺរស្មី ។ ដីសើម ៗ ត្រជាក់ចំណែកសូរសព្ទផ្សេង ៗ ហាក់ដូចជាលាន់ឮឡើងក្នុងខ្សាច់ ។ ពួករតិសុខុមសត្វ

ពួកនិសាចរបេក្សី ពួកទេវគ្គិសត្វទាំងឡាយ ពគ្រីបរកសត្វទាំងនេះ ដូចជា បានចេញរួចពីការរង់ទុក្ខវេទនា គឺកំដៅថ្ងៃក្នុងពេលរសៀល ទឹងពន្លឺព្រះអាទិត្យ ។

នាងអាត់សប្រាតានដ៏តង់ធ្ងុល ប៉េះតែរកក្រេសកក្តាសទាំងប្រហុះលើដីខ្សាច់ ។

នាងឡូឡា គាំងពីចេញទៅ មិនដឹងជាប៉ុន្មានម៉ោងហើយទេ?

ឥឡូវនេះ ដៃនាងអាត់សប្រាតាដែលធ្លាប់តែក្តៅ ព្រោះប៉ះដីខ្សាច់ ស្រាប់តែដឹងថាត្រជាក់ត្រសម ហើយអាកាសក៏អន់ក្តៅ ។ នាងចូលចិត្តថាយប់ហើយ យប់ឆ្ងាយអន្ធការរាសះពេញលើវាលខ្សាច់ទាំងមូល ។

ពេលនេះ គឺ ពេលដែលចាស់ៗតែងនិយាយថាមានបិសាចចេញពីក្នុងដីខ្សាច់ ហើយធ្វើបាបដល់អ្នកដំណើរប្រហែស វង្វេងផ្លូវនាវាលកន្តារ ។ ខណៈនោះ អាត់សប្រាតាក៏ពុំទៃតែគ្រុន ក៏ស្រាប់តែភ័យខ្លាចបែកញើសត្រជាក់អស់ទាំងខ្លួនប្រាណ ។ នាងក៏សត់យល់ថាព្រះអាឡ្លះបោះបង់នាងៈចោលជាពៀងប្រាកដ ។ នាងស្រែកហៅដោយសំឡេងខ្សាវៗ កណ្តាលវាលខ្សាច់ស្ងាត់ត្រឈឹងថា: "ម៉ែ! ឡូឡា!" ។

សំដីទាំងពីរម៉ាត់ចេញពីមាត់នាងនេះ គឺជាសំដីចុងបំផុត ជាសំដីជាទីគោរពដែលនាងថ្វាយចំពោះទេវតាក្នុងវាលខ្សាច់ ហើយសំដីនេះគ្មានឮសូររំពងសោះ ក្នុងរាត្រីស្ងាត់នោះ ។

នៅឯណោះ ឆ្ងាយបន្តិច គេឮសូរឆ្កែព្រៃមួយលូតែឯង ព្រោះលោកខែទើបនឹងរះចេញ ។ ពេលវេលាចេះតែកន្លងទៅ កណ្ដាលយប់ស្ងាត់ឮសូរតែនារីវង្វេងផ្លូវស្រែកហៅថា: “ម៉ែ! ឪឡា!” ។

នាងនឹកភ័យខ្លាចជានិច្ច ។ នាងនឹកម្យ៉ាងទៀតថា បើប្អូននាងមិនឃើញត្រឡប់មកវិញតាមពាក្យសន្យា ដើម្បីជួយស្រង់ជីវិតនាងទេ នោះប្អូននាងប្រាកដជាត្រូវប៉ះលើគ្រោះថ្នាក់ក្នុងកណ្ដាលវាលខ្សាច់ដូចរូបនាងដែរ ។

នាងនឹកស្ដាយណាស់ អំពីការស៊ូប្ដូរជីវិតនេះដែលខ្លួននាងអង្វរទទូចសុំឲ្យប្អូនស្រីនាងនាំមក គឺជាយោបល់ខុសស្រឡះ រួចទឹកភ្នែកស្រាប់តែហូររហាមពេញលើថ្ពាល់ ។ នាងខំប្រឹងវារប្រវាលើដីខ្សាច់ល្បងមើលទៀត ហើយស្រែកហៅថា: “ម៉ែ! ឪឡា!” ។

រួចនាងកំសត់លោគ្រញែងខ្លួនដោយសេចក្ដីភិតភ័យមួយរំពេច នាងស្ទុះថយក្រោយក្រាក ហើយប្រឹងងើបឈរ ព្រោះដៃនាងទើបនឹងដាក់ទៅលើខ្សែមួយស្អិតៗ ត្រជាក់ៗ នាងស្រែកថា: “យី! ពស់!” ។

រួចនាងស្រែកហៅតាមធម្មតាវិស័យ មិនបានជាគិតថា:

— “លោកអើយ ជួយផង!” ។

នៅក្នុងក្រហែងថ្ម មានពស់វែកមួយអាស្រ័យនៅនោះ ។ នាងអន្ទបក្ដុកំសត់ងើបខ្លួនឡើង ពស់នោះវាផ្អើល ហើយវារមកដិតខ្លួននាង ។ កាលណាវាធំក្លិនមនុស្ស ភ្នែកវាទាំងពីរយ៉ាងខៀវស្រងាត់បើកឡើងភ្លឺច្នុះ,

កក្រើកឡើងតាមសំពត់ដែលរុំជុំវិញពោះនាង ។ សត្វនេះកក្រើកកំដៅអ៊ុនៗ ត្រង់ពោះនាង រួចកក្រើកឡើងដល់ត្រង់កនាង នៅជាប់ទ្រោះដុំត្រសាលក្ដុក ទាំងពីរ ។ នាងភ័យពេក ស្ទើរបាត់ស្មារតី នាងចាប់ពស់បំណងទឹង គ្រវាត់ចេញឲ្យឆ្ងាយពីខ្លួន ប៉ុន្តែគ្រវាត់មិនទាន់យឺតពេក ។

នាងបានដឹងថា ហាក់ដូចជាដែកស្រួចពីរមុតសាច់ក្រោមដោះខាង ឆ្វេង ។ ឥឡូវត្រង់មុខរបួសឡើងក្ដៅដូចគេដុត ។ ពិសពស់រត់ចូល ពេញខ្លួននាងហើយជាស្រេច ។ ខណៈនោះ នាងចូលចិត្តថាសេចក្ដី ស្លាប់នឹងមានដល់ខ្លួននាង មិនយូរឡើយ ។ នាងស្រមើស្រមៃហាក់ដូច ជាខ្មោច មច្ចុនៅព័ទ្ធជុំវិញខ្លួន ។ ម៉្លោះហើយ ទឹកភ្នែកអ៊ុនៗហៀរហូរ ចេញព្រាកៗ ពីភ្នែកខ្វាក់ទាំងពីរ ។

កាលនោះនារីកំព្រានឹកឃើញដល់ភូមិកំណើតមានផ្ទះកំពូល មាន ផ្ទះច្នុសៗ មានវត្តអារាមប្រកបដោយផលព្រឹក្សមែកសាខាទ្រឈឹងទ្រឈៃ រួចនឹកដល់កាលដែលនាងត្រាច់ចរ ក្នុងស្រុកស្រែជាមួយនាងឡីឡា ហើយនឹងកិច្ចការអាជីវៈរបស់នាងទាំងពីរ ។ តទៅទៀត នាងហាក់ដូច ជាឮសំដីម្ដាយនិយាយ ឃើញមុខគាត់ញញឹមដាក់ដែលនាងស្រឡាញ់ រកអ៊ីប្រៀបគ្មាន ។ អនុស្សាវរីយ៍ជាអនេកលេចមានឡើងច្របូកច្របល់ គ្នាពេញទាំងសន្ដាននាង គឺដូចជានំក្រៀបដែលនាងចូលចិត្តបរិភោគ ដូច ជាអង្កាំត្បូងកែវប៉ុនៗ ស៊ិតព្រាបដែលនាងចូលចិត្តពាក់នៅក ដូចជាទំនុកធម៌ ដូចជាទំនុកចម្រៀង ដូចជាសំឡេងកូនចៀម កូនពពែ... ។

ការឈឺចាប់ក្នុងទ្រូងត្រង់មុខរបួសអន់បន្តិចហើយ ប៉ុន្តែមានការឈឺចាប់ផ្សេងមួយទៀតចូលមកដល់ ៗ ខ្លួននាងត្រជាក់អស់ហើយ ៗ សេចក្ដីស្លាប់មុខជាទៀងប្រាកដ ៗ ទឹកភ្នែកក៏ឈប់ហូរ ៗ សន្តិសុខយ៉ាងធំរកទីបំផុតគ្មាន ចូលសណ្ឋិតនៅក្នុងដួងហឫទ័យនៃនាង ៗ

នាងពោលខ្សឹប ៗ ថា:

— « សូមឲ្យបំណងរបស់ព្រះអាទិត្យសំរេចចុះ !

ទោះបីការសុខចិត្តរបស់នាងដូចម្ដេចក៏ដោយចុះ ប៉ុន្តែចំណែកកំឡាំងយុវភាព នាំតែតយុទ្ធមិនយល់ព្រមនឹងមច្ចុរាជយ៉ាងយូរ ដែលផ្ដាច់ជីវិតស្ត្រីយនាងដែលទើបនឹងបានអាយុ ២០ ឆ្នាំ ៗ ម៉្លោះហើយទឹកភ្នែកក៏ចាប់ផ្ដើមហូរចេញមកជាថ្មីទៀត ៗ នាងឃើញហាក់ដូចជាមុខប្អូនស្រីនឹងមុខម្ដាយរបស់នាងញញឹមស្ងួតនៅពីមុខនាង ដោយសេចក្ដីព្រួយ ៗ នាងចូលចិត្តថាៈពេលនាងដល់ៈហើយ ៗ នាងតាំងសង្រួមស្មារតីដើម្បីទទួលសេចក្ដីស្លាប់ ៗ នាងដេកសណ្ដូកៈដៃយ៉ាងស្រួលលើដីខ្សាច់បែរមុខមើលមេឃដើម្បីឲ្យព្រះអាទិត្យចាំងរស្មីមកត្រូវ ៗ

ឥឡូវនេះរហសភាពដ៏អស្ចារ្យ យ៉ាងចុះពេញក្នុងសរីរកាយនាងហើយជាស្រេច ៗ កាលព្រះអរុណៈ ចាំងចោលរស្មីបំព្រាងលើផ្ទៃខ្សាច់បំភ្លឺព្រះធរណី ចិត្តអាតស្ត្រាតាក៏ចាកចេញផុតពីរាងកាយក្នុងវេលានោះ ៗ

(មានត)

# រឿងបល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតំណាល

## លោកសមិន មុត្យុងជិម: តែង

## លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ដល់ពេលយប់ ព្រះរាជាទ្រង់បានចាត់ឲ្យរៀបចំសុរានិងមេរ័យជាច្រើនយ៉ាង សាច់, ត្រី, វត្ថុឆ្អិនៗ, នំប៉័ង, បាយចំអិនលាយទឹកឃ្មុំនិងស្ករ, ភោជនាហារ, សម្ល, ទឹកដោះគោខាប់, ទឹកដោះគោរាវ, ខ្លាញ់គោចំរាញ់ឲ្យស្អាត, ទឹកខ្ទាញ់ ដល់ពេលយប់គោ, កំញាន, កម្រងផ្កា, ធូប, គ្រឿងក្រអូបផ្សេងៗ . . . ល . . . សម្រាប់បូជាចំពោះវេតាលៈអគ្គី; ព្រះអគ្គីទ្រង់បានចាត់ឲ្យយកវត្ថុទាំងអស់នោះ ទៅដំកល់នៅព្រះរាជរោង ហើយព្រះអគ្គីទ្រង់គង់ចាំនៅក្រឡាព្រះបន្ទំ ។

វេតាលៈអគ្គី បានចូលទៅក្នុងព្រះរាជរោង លើកព្រះខ័នឡើង បំណងនឹងពិឃាតព្រះបាទវិក្រមាទិត្យ មានព្រះឱង្ការទៅកាន់វេតាលៈអគ្គីថា: «ម្នាលវេតាលៈអគ្គី! ចូរអ្នកស្តាប់យើង! ដោយហេតុថាអ្នកឯងមកទីនេះ បំណងនឹងសម្លាប់យើង ។ គត់មានសង្ស័យថា ត្រង់បំណងអ្នកឯងមុខជានឹងមិនបានសម្រេចនោះឡើយ តែភោជនាហារទាំងនេះយើងឲ្យគេប្រមូលយកមកដំកល់ទុកនៅទីនេះដើម្បីអ្នក; ចូរអ្នកបរិភោគ

អាហារទាំងអស់នេះសិន រួចសឹមអ្នកសម្លាប់យើងជាក្រោយ ” ។ វេតាលៈអគ្គី កាលបានស្ដាប់ព្រះរាជឧង្ការព្រះបាទវិក្រមាទិត្យហើយ ក៏អាស្រ័យអាហារទាំងនោះ មានសេចក្ដីពេញចិត្តនឹងព្រះអង្គក្រៃពេក ក៏ទូលថា “ទូលបង្គំសប្បាយចិត្តនឹងព្រះអង្គពន់ពេក ទូលបង្គំសូមថ្វាយប្រទេសអវន្តីនេះដល់ព្រះអង្គ; ទូលបង្គំសូមទុកទ្រង់ជាព្រះមហាក្សត្រិយ៍មួយ ហើយសូមឲ្យទ្រង់សោយរាជសម្បត្តិជាសុខសប្បាយចុះ ។ តែសូមទ្រង់ចាត់ឲ្យធ្វើម្ហូបអាហារមានឱជារសបែបនេះ ទុកឲ្យទូលបង្គំបរិភោគរាល់ថ្ងៃកុំខាន” ។ ដល់វេតាលៈអគ្គីក្រាបទូលព្រះបាទវិក្រមាទិត្យហើយ ក៏វិលត្រឡប់ទៅគេហដ្ឋានវិញ ។

ព្រឹកឡើង ព្រះមហាក្សត្រិយ៍ទ្រង់បានបំពេញព្រះរាជករណីយកិច្ច ទ្រង់បានចូលទៅក្នុងព្រះរាជមន្ទីរប្រឹក្សា ។ ពួកទីប្រឹក្សានិងអ្នកឯទៀតបានឃើញព្រះមហាក្សត្រិយ៍ ក៏គិតក្នុងចិត្តថា: “បើព្រះមហាក្សត្រិយ៍អង្គនេះរួចពីកណ្ដាប់ដៃវេតាលៈអគ្គី យើងយល់ថាព្រះអង្គជាបុគ្គលដ៏ឧត្ដម” ។ កាលពិចារណាយ៉ាងនេះហើយ ពួកទីប្រឹក្សានិងអ្នកឯទៀត ក៏សំដែងសេចក្ដីគារវៈចំពោះព្រះអង្គ, បានយកចិត្តទុកដាក់បម្រើព្រះអង្គឥតប្រមាទសោះឡើយ ហើយបំពេញករណីយកិច្ចសព្វៗខ្លួន ។

ព្រះបាទវិក្រមាទិត្យ ទ្រង់បានធ្វើឲ្យពួករដ្ឋមន្ត្រីនិងអ្នកឯទៀតស្ដាប់ព្រះរាជឧង្ការ ដោយសេចក្ដីកោតខ្លាចផង, ករុណាផង, ព្រះអង្គបានបំពេញនូវរាជធម៌គ្រប់យ៉ាង តាមច្បាប់នយោបាយនិងបទបញ្ញត្តិក្រម

ព្រាហ្មណ៍ ៗ រាល់ថ្ងៃ, ព្រះអង្គបានចាត់ឲ្យរៀបចំម្ហូបអាហារដូចមុនទុក សម្រាប់វេតាលៈអគ្គី ៗ តែតមក, ព្រះអង្គទ្រង់បានធ្វើឲ្យវេតាលៈអគ្គី នៅក្រោមព្រះរាជបញ្ញារបស់ព្រះអង្គ ដោយប្រើមធ្យោបាយដូចខាងក្រោម ៗ

មានសម័យថ្ងៃមួយ ក្នុងពេលអភិទេសកាល, វេតាលៈអគ្គី កាលបានបរិភោគអាហារទាំងនោះ មានសេចក្ដីរីករាយសប្បាយចិត្តហើយមិនបានវិលត្រឡប់ទៅគេហដ្ឋានវិញ ៗ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលសួរទៅវេតាលៈអគ្គីថា: "នុវេតាលៈ តើអ្នកឯងមានសមត្ថភាពធ្វើអ្វីបានខ្លះ? មានវិជ្ជាអ្វីខ្លះ?" ៗ វេតាលៈអគ្គីទូលតបវិញថា: "អ្វីដែលនៅក្នុងដួងវិញ្ញាណរបស់ទូលបង្គំ ៗ បង្គាប់បានទាំងអស់, ទូលបង្គំដឹងទាំងអស់" ៗ ព្រះអង្គទ្រង់ត្រាស់តបថា: "ចូរអ្នកឯងប្រាប់យើង, មើលចំមកយើង តើជីវិតៈយើងមានចិរវេលាត្រឹមណា?" ៗ វេតាលៈ-អគ្គីក្រាបទូលថា: "ព្រះជន្មាយុព្រះអង្គមានមួយរយព្រះវស្សា" ៗ ព្រះបាទវិក្រមាទិត្យមានព្រះឧង្ការតបថា: "ក្នុងជីវិតៈយើងមានអកុសលពីរយ៉ាងជាកិច្ចមិនល្អសោះឡើយ; យើងប្រាថ្នាឲ្យអ្នកឯងធ្វើអាយុយើងឲ្យបានកើនចំនួនមួយឆ្នាំ ក្នុង ១០០ ឆ្នាំ, ឬបន្ថយមួយឆ្នាំក្នុង ១០០ ឆ្នាំចេញ បានឬទេ? ៗ វេតាលៈអគ្គី ក្រាបទូលថា: "ព្រះអង្គប្រកបដោយសុក្រិតភាពនូវព្រះរាជចរិយា សោភ័ណ, សប្បុរស, អាណិតអាសូរអ្នកដទៃ, សុចរិត ឈ្នះពាលាទិកិលេស, ពួកអាទិទេព និងព្រាហ្មណ៍តែងគោរពព្រះអង្គ: ជីវិតរបស់ព្រះអង្គពេញទៅដោយសេចក្ដីសុខ, ទូលបង្គំមិន

អាចបង្កើន ឬបន្ថយបានឡើយ" ។ ព្រះបាទវិក្រមទិត្យកាលទ្រង់ស់រនាក់ចរវេតាលៈអគ្គី ក៏មានព្រះទ័យសោមនស្សពន់ពេក; វេតាលៈ-អគ្គី ក៏ត្រឡប់ទៅគេហដ្ឋានវិញ ។

តាំងពីថ្ងៃនោះមក ព្រះមហាក្សត្រិយ៍ មិនបានចាត់ឲ្យរៀបចំអាហារក្នុងពេលរាត្រី សម្រាប់វេតាលៈអគ្គីទេ, តែព្រះអង្គប្រុងប្រៀបតស៊ូនឹងវេតាលៈនេះ ។ បន្តិចទៀត វេតាលៈមកដល់មិនឃើញមានអាហារដាក់ទុកនៅទីនោះ ឃើញតែព្រះរាជអាកប្បកិរិយាប្រុងប្រៀបនឹងធ្វើសង្គ្រាមទៅវិញ, ក៏មានចិត្តក្រោធជាខ្លាំងហើយពោលថា: "ម្ដេចពាល, ឥឡូវនេះ ម្ដេចក៏អ្នកឯងមិនរៀបចំអាហារឲ្យខ្ញុំបរិភោគ?" ។ ព្រះបាទ-វិក្រមទិត្យមានព្រះឱង្ការតបទៅវេតាលៈវិញថា: "បើអ្នកឯងមិនអាចបន្ថយចិរវេលានៃជីវភាពយើង ឬបន្ថយជីវិតយើងបានទេ តើឲ្យយើងរៀបម្ហូបអាហារជាទំនួលឲ្យអ្នកឯងបរិភោគ មានផលប្រយោជន៍អ្វី?" ។ វេតាលៈតបថា: "ម្ដេចក៏អ្នកឯងពោលដូចនេះ? អ្នកឯងមកតស៊ូគ្នាក្នុងកាលឥឡូវនេះ គឺក្នុងថ្ងៃនេះហើយដែលអញបរិភោគអ្នកឯង" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់នូវពាក្យវេតាលៈនេះហើយទ្រង់ព្រះក្រោធជាខ្លាំង ព្រះអង្គទ្រង់ក្រោកឡើង ដើម្បីតយុទ្ធតាមក្បួនរណវិជ្ជាជាច្រើនយ៉ាងនឹងវេតាល ក្នុងរយៈវេលាជាច្រើននាទី ។ វេតាលៈបានពិសោធន៍ស្ដេចនេះដ៏ច្បាស់ថា 'ព្រះអង្គទ្រង់មានព្រះរាជ-ពលភាពនិងព្រះវិរិយភាពដ៏អស្ចារ្យក្នុងការតយុទ្ធនេះ" ។ វេតាលៈមាន

សេចក្តីពេញចិត្តក៏ពោលថា "ឱព្រះមហាក្សត្រិយ៍ ព្រះអង្គមានព្រះរាជពលភាពជាអស្ចារ្យ ទូលបង្គំជាខ្ញុំមានសេចក្តីពេញចិត្តនឹងព្រះវិរិយភាពរបស់ព្រះអង្គ ចំពោះការតយុទ្ធនេះណាស់, សូមព្រះអង្គទ្រង់មានព្រះរាជឱង្ការ តើព្រះអង្គមានព្រះរាជបំណងចង់បានអ្វីពីទូលបង្គំជាខ្ញុំ" ។ ព្រះមហាក្សត្រិយ៍មានព្រះបន្ទូលថា: "បើអ្នកឯងស្រុះស្រួលនឹងយើង ត្រូវអ្នកយល់ព្រមថា ក្នុងកាលអនាគតបើយើងនឹកដល់អ្នកឯង ឲ្យអ្នកឯងមកជិតយើងភ្លាម" ។ វេតាលៈ ក៏យល់ព្រមតាមព្រះរាជបំណង រួចក៏វិលត្រឡប់ទៅគេហដ្ឋានវិញ ។

ដល់ព្រឹកស្អែក ព្រះរាជាវិក្រមាបានដឹងរឿងរ៉ាវនេះ ពីព្រះឱស្ឋព្រះមហាក្សត្រិយ៍ ហើយបានយល់ជាក់ច្បាស់នូវសន្តតិវង្សនៃព្រះអង្គ ក៏ចាត់ឲ្យធ្វើមហាសន្និបាតជាឧឡារិក ដើម្បីនឹងអភិសេកព្រះអង្គឲ្យសោយរាជ្យ ជាស្តេចនៅប្រទេសនោះ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានទទួលព្រះរាជាភិសេកហើយ ក៏បានសោយរាជសម្បត្តិជាសុខ មិនបានទ្រង់ព្រះចិន្តាថារាជសម្បត្តិនោះមានបន្ទាត់ទុក្ខភ័យ ឬលំបាកផ្សេងៗឡើយ ។

ក្នុងពេលនោះ មានយោគីម្នាក់មកដល់ ហើយក្រាបទូលថា: "ឱមហារាជ! កិច្ចការដែលទូលបង្គំសូមទាំងប៉ុន្មាន សូមព្រះអង្គយល់ព្រមតាមទូលបង្គំៗ នឹងថ្វាយពាក្យមួយដល់ព្រះអង្គ" ។ ព្រះមហាក្សត្រិយ៍មានព្រះបន្ទូលថា: "ឱយោគី, អ្នកចង់បានព្រះរាជទ្រព្យ របស់យើងទាំងប៉ុន្មាន ឬជីវិតយើង យើងនឹងប្រគល់ជូនអ្នកដូចបំណង,

យើងនឹងធ្វើតាមបង្គាប់អ្នកទាំងអស់" ។ យោគីនោះក្រាបទូលថា: "ទូលបង្គំមានកិច្ចត្រូវធ្វើពិធីបូជាសព; សូមព្រះអង្គយាងទៅជួយទូលបង្គំកុំខាន" ។ ព្រះមហាក្សត្រិយ៍ទ្រង់យល់ព្រម, យោគីនោះក៏នាំព្រះអង្គទៅកាន់អាឡាហនដ្ឋាន ។ លុះស្ដេចទ្រង់យាងទៅដល់ទីនោះ យោគីក៏បង្គាប់ព្រះអង្គថា: "ព្រះអង្គ, ចម្ងាយពីទីនេះចំនួនពីរក្រុស:, មានរុក្ខជាតិមួយដើមឈ្មោះសំសបៈ គេបានយកសាកសពមួយទៅចង; សូមព្រះអង្គយាងទៅយកសាកសពនោះក្នុងកាលឥឡូវនេះ" ។ យោគីនោះលុះបង្គាប់ព្រះមហាក្សត្រិយ៍ហើយ ក៏ទៅស្ថិតនៅខាងទិសបូព៌ានៃបាធាដែលតាំងនៅមាត់ស្ទឹង យយ៌ា ហើយសូត្រនូវមន្ត្រ(១) ត្រង់បូជនិយដ្ឋាននាងអាទិទេវកាលិកា ។ ព្រះមហាក្សត្រិយ៍ទ្រង់យាងទៅដល់ព្រឹក្សជាតិ សំសបៈ ទ្រង់ឡើង ទៅលើដើមឈើនោះហើយយកព្រះខ័នកាត់ផ្ដាច់ចំណង ដែលចងសាកសព ៗ ធ្លាក់ច្រុះមកដល់ដី ។ តែដល់ព្រះមហាក្សត្រយ៍ទ្រង់ចុះពីលើរុក្ខជាតិមកដល់ដី សាកសពនោះឡើងទៅលើរុក្ខជាតិនោះវិញ ហើយធ្វើឲ្យមានសភាពចងព្យួរដូចកាលពីមុន ។

(មានត)

---

១ មន្ត្រ (Mantras) វិជ្ជាអាថ៌កំបាំងហើយមានឥទ្ធានុភាពឲ្យសម្រេចទៅតាមបំណង ដូចជាគាថាកំភ្លើងជាដើម, យើងហៅថា មន្តអាគម ។

# កំណត់និងប្រវត្តិការណ៍

## បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

### របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៩២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហង់-ជួប នាមឆាយា ជោតគ្គោ កើតឆ្នាំរក អាយុ ៥៤ វស្សា ៣៣ ជាចៅអធិការ វត្តអង្គព្រះស្តេច ឃុំបឹងក្រាញ់ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អាំង-អ៊ុច នាមឆាយា សុធម្មបញ្ញា កើតឆ្នាំច អាយុ ៥២ វស្សា ៣០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-សៀន នាមឆាយា ជោតគ្គោ កើតឆ្នាំម្សាញ់ អាយុ ៤៥ វស្សា ២២ ជាគ្រូសូត្រឆ្វេង-វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប្រាក់-ឌិត នាមឆាយា សុវណ្ណជោត កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៦ ជាគ្រូសូត្រឆ្វេង វត្តអង្គគោល ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ

ប៉ែន-នុម នាមធាយា នន្ទត្រេ កើតឆ្នាំមមែ អាយុ ៥៥ វស្សា ៣២ ជាចៅអធិការ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហួ-ឃួយ នាមធាយា នន្ទជោត កើតឆ្នាំកុរ អាយុ ៥១ វស្សា ២៧ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រាប-ម៉ម នាមធាយា បញ្ញាកេសរ កើតឆ្នាំថោះ អាយុ ៥៩ វស្សា ៣៩ ជាចៅអធិការ វត្តប្រាង្គណ៍អណ្តែត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មួន-សុខ នាមធាយា ព្រហ្មជោត កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ក្រូច-ឡុង នាមធាយា សុវណ្ណបញ្ញា កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាគ្រូស្រូត្រស្តាំ វត្ត-ឃុំ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ស្រៃ នាមធាយា ជោតបញ្ញា កើតឆ្នាំច អាយុ ៥២ វស្សា ៣២ ជាចៅអធិការ វត្តអង្គក្បូរ ឃុំ-ស្រុក-ខេត្តដដែល ។ (មានត)

# ដំណើរទស្សនានៃឯកឧត្តម អ៊ូ-នូ

នៅថ្ងៃទី ១៧ ធ្នូ ១៩៥៤ ម៉ោង ១៥ នឹង ៣០ នាទី ជាថ្ងៃសុភមង្គល ដោយវិទ្យាឋាន ពុទ្ធសាសនបណ្ឌិត្យ បានទទួលភ្ញៀវពិសេស គឺ ឯ. ឧ. អ៊ូ- នូ រដ្ឋមន្ត្រីទី ១ នៃសហភាពភូមា ព្រមទាំងលោកចំទាវ នឹងសហការី រួមជា ៩ រូប ដែលអញ្ជើញមកទស្សនាវិទ្យាឋាននេះ ។

វេលានោះ, យើងបានឃើញឥស្សរជន គឺ ឯ. ឧ. ប៉ាល់- ឌួន រដ្ឋលេខាធិការ ក្រសួងធម្មការ, លោក ឃឹន- ចឹម អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ, លោកឈុន - យឺន នាយកមន្ទីរ នីតិបុគ្គលិកក្រសួងធម្មការ ព្រមទាំងក្រសួងពុទ្ធសាសនបណ្ឌិត្យ ដែលយើងសូមអភ័យទោស ដោយចេញនាមពុំសព្វគ្រប់ បានមករង់ចាំទទួល ឯ. ឧ. អ៊ូ - នូ នៅកើយខាងមុខវិទ្យាឋាន ហើយបាននាំចូលទៅទស្សនាគ្រប់កន្លែងដ៏គួរ ។

យើងសំគាល់ឃើញ ឯ. ឧ. អ៊ូ - នូ ស្លៀកសំពត់អន្លូញសំឡុយព័ណ៌ខៀវប្រផេះ ពាក់អាវស កម្ដុលក្បៀវក្ដុំ ពាក់ឈ្នួតក្បាលស, លោកចំទាវស្លៀកសំពត់អន្លូញសំឡុយព័ណ៌ខ្ចាញ់ក្ដាម ពាក់អាវបំពង់ខ្លី ដៃវែងព័ណ៌ស ជាសំលៀកបំពាក់នឹងសាច់សំពត់របស់ជាតិភូមា ។

កាលចូលទស្សនាវិទ្យាឋានពុទ្ធសាសនបណ្ឌិត្យ ឯ. ឧ. អ៊ូ- នូ បានចាប់អារម្មណ៍ជាច្រើន ដោយឃើញ ឯ. ឧ. ពិនិត្យមើលទីទាំងឡាយ ជាដើមគឺ ប្រកាសអក្សរខ្មែរដែលនៅលើទូដាក់ស្លាកប្រាប់ឈ្មោះគម្ពីរ បានឲ្យអ្នកប្រែភាសាអានអក្សរនោះជាសំឡេងខ្មែរនឹងភូមាជូនស្ដាប់មួយស្របក់ធំ, ហើយទើបទៅទស្សនាទីដំកល់សាស្ត្រាស្លឹករឹត ដែលនៅជុំវិញការិយាល័យនៃ អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ។

បន្ទាប់ពីនេះ, បាននាំទៅទស្សនាកន្លែងក្រុមជំនុំព្រះត្រៃបិដក, ហើយហួសទៅទស្សនា សាលាបាលីជាន់ខ្ពស់, លុះចូលទៅដល់ទីខាងមុខ ដោយ ឯ. ឧ. អ៊ូ - នូ ព្រមទាំងសហការី ជាពុទ្ធជនក៏បានគោរពព្រះសង្ឃជាបាងហ្វាងនឹងសាស្ត្រាចារ្យ ដោយកាយវិការដ៏សមរម្យ ។ យើងចាំបានថាមុននឹងចូលទៅ, ឯ.ឧ. អ៊ូ- នូ ឃើញព្រះសង្ឃព្រះបាទទទេ ក៏ងាករកទីទាបឈរ សុំទោស ហើយទើបឱនកាយថ្វាយបង្គំ ។ ចំណែកសភាពស្ត្រី ៣ រូបមានលោកចំទាវ អ៊ូ -នូ ជាដើម ឃើញដោះស្បែកជើងលុតជង្គង់ទាំងពីរឱនក្បាលជិតដល់ដីលើកដៃថ្វាយបង្គំដោយ ទន់ភ្លន់ ។ លុះគោរពហើយទើបចូលទៅទស្សនាសមណសិស្សដែលកំពុងរៀនត្រៀបត្រា, រួចថ្វាយបង្គំលាត្រឡប់ទៅវិញដោយរីករាយ ។

អវសាននៃការទស្សនានេះ, អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បានជូន ឯ. ឧ. អ៊ូ- នូ នូវព្រះពុទ្ធរូបសម្រិទ្ធិគ្រាផ្ចាញ់មារ ១ ព្រះអង្គដែលរកបានដោយក្រ ជារចនាខ្មែរបុរាណដែលមាន ក្នុងវិទ្យាឋានពុទ្ធសាសនបណ្ឌិត្យ ដើម្បីជាអនុស្សាវរីយ៍ ។ យើងសំគាល់ឃើញ ឯ. ឧ. អ៊ូ- នូ មានអំណរចំពោះអំណោយនេះណាស់ដោយលោកចេះតែលើកបិទទូលលើសិរសាញឹយ ៗ ។

*ពុទ្ធសាសនបណ្ឌិត្យ*